# សម្ភាសន៍ជាមួយ ពេជ្រ ហេន ភេទស្រី អាយុ៥៦ឆ្នាំ

## មុខងារសម័យខ្មែរក្រហមៈ កម្មករពោនចក្រ(ត-៥)

## ស្រុកកំណើតនៅភូមិស្វាយទោង ឃុំជ្រៃបាក់ ស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង

## រស់នៅភូមិសែនសុខ ឃុំទំនប់ដាច់ ស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ

## ថ្ងៃទី ១៨ ខែធ្នូ ឆ្នាំ២០១៣

## សម្ភាសន៍ដោយៈ ម៉ម សុវណ្ណ

## ០១:៥១:៥៦

## ៥២ទំព័រ

ហេនៈ តាំងពីនៅក្មេង តាំងពីតូច ។

សុវណ្ណៈ អត់អីទេមីង ដំបូងខ្ញុំសុំណែនាំខ្លួនម្តងទៀត ខ្ញុំសុំជំរាបសួរមីង ខ្ញុំឈ្មោះ ម៉ម សុវណ្ណ ខ្ញុំជាបុគ្គលិកនៅក្នុងគម្រោងរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ហើយមកថ្ងៃនេះ នៅថ្ងៃទី១៨ ខែ១២ ឆ្នាំ២០១៣ ហើយខាងខ្ញុំមកជួបមីងគឺក្នុងគោលបំណងចង់សរសេរសៀវភៅមួយហៅថាមគ្គុទេសន៍ស្រុកអន្លង់វែង ជាសៀវភៅបែបទេសចរណ៍មួយដើម្បីឲ្យទេសចរណ៍គេស្គាល់ ហើយក៏ដូចជាក្មេងៗជំនាន់ក្រោយគេស្គាល់រឿងរ៉ាវអន្លង់វែងដែរ ហើយជាការចងក្រងប្រវត្តិសាស្ត្រមួយដូចជាចៅមីង ដូចជាកូនមីងឲ្យដឹងពីរឿងរ៉ាវ ។ អីចឹងដំបូងខ្ញុំចង់ឲ្យមីងណែនាំខ្លួនថាមីងឈ្មោះអីគេ?

ហេនៈ ខ្ញុំឈ្មោះ ពេជ្រ ហេន ។

សុវណ្ណៈ មីងសព្វថ្ងៃអាយុប៉ុន្មានហើយ?

ហេនៈ អាយុហាជាងហើយ ។

សុវណ្ណៈ ហាប៉ុន្មានមីង?

ហេនៈ ៥៦ ។

សុវណ្ណៈ មីងចាំទេថាមីងកើតឆ្នាំណា?

ហេនៈ មិនដឹងឆ្នាំណាទេអត់ចាំ ។

សុវណ្ណៈ មួយពាន់ប្រាំបួនរយប៉ុន្មាន?

ហេនៈ បើពុកខ្ញុំគិតមួយពាន់ប្រាំបួនសែប៉ុន្មានទេ ។

សុវណ្ណៈ អត់ចាំទេមីង?

ហេនៈ ចាំ! អត់ចាំ ។

សុវណ្ណៈ នៅភូមិនេះគេហៅភូមិអីគេមីង?

ហេន៖ ភូមិសែនសុខ ។

សុវណ្ណៈ ឃុំ?

ហេន៖ ឃុំទំនប់ដាច់ ។

សុវណ្ណៈ ស្រុក?

ហេន៖ ស្រុកត្រពាំងប្រាសាទ ។

សុវណ្ណៈ ចុះពីមុនមីងមានស្រុកកំណើតនៅណាដែរ?

ហេន៖ នៅខេត្តកំពង់ឆ្នាំង ។

សុវណ្ណៈ នៅភូមិអីគេមីង?

ហេន៖ ភូមិស្វាយទោង ។

សុវណ្ណៈ ឃុំ?

ហេន៖ ឃុំជ្រៃបាក់ ស្រុករលាប្អៀរ ។

សុវណ្ណៈ ខេត្តកំពង់ឆ្នាំង?

ហេន៖ ចា៎!

សុវណ្ណៈ គ្រួសារមីងគាត់ឈ្មោះអីគេមីង?

ហេន៖ ឈ្មោះ សុខ កំសាន ។

សុវណ្ណៈ គាត់អាយុប៉ុន្មានមីង?

ហេន៖ អាយុ៥៨ ។

សុវណ្ណៈ គាត់សព្វថ្ងៃធ្វើអីគេ?

ហេន៖ មុខរបររកស៊ីបើមានកំលាំងខ្លះរកអារឈើ គាត់ទៅជួយអារឈើ បើគ្មានទេក៏ទៅបោកវល្លិ៍ មុខរបរធ្វើស្រែ ចំការគ្មានទេ ។

សុវណ្ណៈ អ៊ីចឹងកសិករ?

ហេន៖ ចា៎!

សុវណ្ណៈ តែក្រៅពីធ្វើស្រែចំការទៅជួយបោចវល្លិ៍ និងអារឈើ?

ហេន៖ ចា៎!

សុវណ្ណៈ ចុះមីងធ្វើអីសព្វថ្ងៃ មុខរបរមីង?

ហេន៖ ជួយមើលកូនចៅ ។

សុវណ្ណៈ ហ្នឹងទំនេរពីការងារធំ?

ហេន៖ ចា៎!

សុវណ្ណៈ	ចុះការងារប្រចាំមីងធ្វើអីគេ?

ហេនៈ	ធ្វើតែស្រែដូចតែគ្នា ។

សុវណ្ណៈ	កសិករ?

ហេនៈ	ចា៎!

សុវណ្ណៈ	ចុះពេលទំនេរពីធ្វើស្រែ?

ហេនៈ	គ្មានធ្វើអីទេ មានតែដាំបន្លែតិចតួច ។

សុវណ្ណៈ	មានរកក្រៅទេមីង?

ហេនៈ	អត់មានរកអី អត់ដឹងរកអី មិនដឹងរកអីស្រុកនេះ ។

សុវណ្ណៈ	មីងមានកូនប៉ុន្មាននាក់?

ហេនៈ	កូន៥ ។

សុវណ្ណៈ	ប្រុសប៉ុន្មាន ស្រីប៉ុន្មាន?

ហេនៈ	ប្រុសតែមួយទេ ស្រី៤ មានគ្រួសារហើយនៅតែពៅមួយ ។

សុវណ្ណៈ	ពៅប្រុស?

ហេនៈ	ពៅស្រី ។

សុវណ្ណៈ	អីចឹង៤នាក់ទៀតមានគ្រួសារអស់ហើយ?

ហេនៈ	ចា៎!

សុវណ្ណៈ	ហើយសព្វថ្ងៃនៅសល់កូនពៅអាយុប៉ុន្មាន?

ហេនៈ	អាយុ២០ឆ្នាំ ។

សុវណ្ណៈ	រៀនថ្នាក់ទីប៉ុន្មាន?

ហេនៈ	ឈប់រៀនហើយ ។

សុវណ្ណៈ	មីងមានបងប្អូនប៉ុន្មាននាក់?

ហេនៈ	បងប្អូនច្រើនតែមកទីណាត់ទីណែងមកតែខ្ញុំមួយ ។

សុវណ្ណៈ	បងប្អូនបង្កើត?

ហេនៈ	បងប្អូនខ្ញុំមាន៨នាក់ ។

សុវណ្ណៈ	ប្រុសប៉ុន្មាន ស្រីប៉ុន្មាន?

ហេនៈ	មានតែស្រី៣នាក់ ក្រៅពីហ្នឹងសុទ្ធតែប្រុស ។

សុវណ្ណៈ	ស្រី៣ ប្រុស៥!

ហេនៈ	ចា៎! ខ្ញុំបងគេបង្អស់ ។

សុវណ្ណៈ ចុះឪពុកឈ្មោះអីគេ?

ហេនៈ ត្រកូលគាត់អត់ចាំ ដាក់ឈ្មោះមៀន ។

សុវណ្ណៈ ហើយម្ដាយមីង?

ហេនៈ ម្ដាយខ្ញុំឈ្មោះ លឿង ព្រីង ។

សុវណ្ណៈ សព្វថ្ងៃគាត់នៅរស់ ឬខូចហើយ?

ហេនៈ អត់ដឹង បែកគ្នាយូរ តែខ្ញុំសន្និដ្ឋានថាគាត់ខូចហើយសម័យហ្នឹង ។

សុវណ្ណៈ ដែលទៅលេងស្រុកកំណើតទេមីង?

ហេនៈ អត់ ។

សុវណ្ណៈ មូលហេតុអីមីង?

ហេនៈ មូលហេតុមកពីយើងខ្វះខាតថវិការទៅ ។

សុវណ្ណៈ ចុះបងប្អូនដឹងដំណឹងគ្នាថានៅរស់?

ហេនៈ អត់ដឹងទេ ។

សុវណ្ណៈ តាំងពីយើងខ្មែរក្រហមមកយើងមានដែលទាក់ទងរកបងប្អូនទេ?

ហេនៈ ពី៧៦ខ្ញុំអាចដឹងខ្លះ ខ្ញុំសរសេរសំបុត្រពីនេះទៅ គេសរសេរសំបុត្រមកវិញថាគេនៅរស់ទាំងអស់គ្នា ដល់ខ្ញុំតបសំបុត្រទៅវិញក៏បាត់រហូតទៅ លែងដឹងដំណឹង ។

សុវណ្ណៈ អីចឹងយើងបាត់ដំណឹងបងប្អូនតាំងពី៧៦មក?

ហេនៈ តាំងពីហ្នឹងមក ។

សុវណ្ណៈ មកទល់ពេលនេះអត់ដឹងដំណឹងថាបងប្អូននៅណាទេ?

ហេនៈ អត់ តែគេឡើងមកម្ដងៗតាំងពីប៉ែតប៉ុន្មានទេ ៨៣-៨៤ស៊ើបសួរគេទៅនៅភូមិជាមួយគេថាស្គាល់ គេថាឃើញ ដល់ពេលហើយពីហ្នឹងលែងដឹងដំណឹង ។

សុវណ្ណៈ កាលមីងនៅក្មេងឈប់រៀនថ្នាក់ទីប៉ុន្មានដែរមានចាំទេ?

ហេនៈ អត់មានថ្នាក់ផង អត់បានរៀនទេ អត់បានរៀនទេ រៀនតែក្នុងអង្គភាព១-២ម៉ោង អាចមើលរួចខ្លះបានតិចៗ បើព្យាយាមទៅចេះមើលបានច្រើន ។

សុវណ្ណៈ អីចឹងមីងមូលហេតុអីមីងអត់បានទៅរៀនកាលពីក្មេង?

ហេនៈ នៅក្មេងព្រោះស្រុកគេរដ្ឋប្រហារមករហូត ក៏ខ្ញុំនៅពីក្មេងសាលាឆ្ងាយ នៅធ្វើការឆ្ងាយពីសាលា ក៏មិនហ៊ានទៅរៀនឆ្ងាយពេក បានរៀនអក្សរកម្មក្នុងភូមិតិចតួច ។

សុវណ្ណៈ តែបានចូលសាលាទេ?

ហេនៈ អត់ទេ អត់បានចូលទេ ។

សុវណ្ណៈ រៀនអក្ខរកម្មតិចតួចរៀននៅក្នុងភូមិរៀនយ៉ាងម៉េចទៅមីង?

ហេនៈ យើងរៀនអក្សរហ្នឹងស្រះក-ខ រៀនបំបែកជាស្រះ ចេះមើលតិចតួច យើងរដ្ឋប្រហារ ហើយរៀនត្រឹមមួយម៉ោងៗអីចឹងទៅ ចេះតែចាំ ចេះយល់ ហើយមើលបានខ្លះ ។

សុវណ្ណៈ អ្នកណាគេបង្រៀនកាលហ្នឹងនៅក្នុងភូមិ?

ហេនៈ គ្រូច្រើន មិនដឹងជាគ្រូណាៗខ្លះទេ គេមានអ្នកចំណេះដឹងខ្ពស់ទៅគេបង្រៀនយើងទៅមួយម៉ោង ថ្ងៃមួយម៉ោង យប់មួយម៉ោងចេះតែរៀន អត់មានសាលា សាលាឆ្ងាយក៏មិនបានទៅរៀន ។

សុវណ្ណៈ ជីវភាពគ្រួសារមីងដែលកាលហ្នឹងមីងនៅក្មេងៗជាមួយឪពុកម្តាយ ជីវភាពយ៉ាងម៉េចមីងខ្វះខាត ឬមិនខ្វះខាតទេ?

ហេនៈ ខ្វះខាត ក្រដែល តែវាមិនក្រណាស់ណាប៉ុន្មានទេ គ្រាន់បានទប់ទល់ទិញអង្ករគីឡូហូបធ្វើការ ។

សុវណ្ណៈ កាលហ្នឹងឪពុកម្តាយមីងធ្វើអីគេ កាលមីងនៅជាមួយគាត់?

ហេនៈ ធ្វើចំការ ធ្វើស្រែដូចតែគ្នាទប់ទល់បានតិចតួច ក្រៅពីធ្វើស្រែចំការអារឈើ អារណាដៃគេរកអារឲ្យគេទៅ ។

សុវណ្ណៈ មីងនៅក្មេងមីងដែលនឹកស្រម៉ៃថាមីងធំឡើងចង់ធ្វើនេះ ធ្វើនោះ ធ្វើពេទ្យ ធ្វើគ្រូបង្រៀនដែលនឹកស្រម៉ៃទេ?

ហេនៈ ចេះស្រម៉ៃ តែវាមិនបានដូចគោលបំណង ស្រុករដ្ឋប្រហារទៅ ។

សុវណ្ណៈ កាលហ្នឹងមីងនឹងស្រម៉ៃថាចង់ធ្វើអីគេ កាលនៅក្មេង ។

ហេនៈ ស្រម៉ៃចង់ធ្វើពេទ្យ ។

សុវណ្ណៈ មូលហេតុអីមីងចង់ធ្វើពេទ្យ?

ហេនៈ ឃើញពូខ្ញុំគាត់នៅធ្វើពេទ្យ ព្យាយាមមើលអ្នកជំងឺ ព្យាបាលអ្នកជំងឺ ឃើញអីចឹងចង់ចេះចង់ដឹង ។

សុវណ្ណៈ ដល់ក្រោយមករដ្ឋប្រហារ មីងថាមូលហេតុអីរដ្ឋប្រហារ? ម៉េចយើងដឹងថារដ្ឋប្រហារ?

ហេនៈ កាលហ្នឹងខ្ញុំដឹងដែលហើយ ដឹងថាគេរដ្ឋប្រហារគេបាតុកម្មហ្នឹងក៏នឹកឃើញ ពុកម៉ែថាគេបាតុកម្មទម្លាក់សម្តេចឪចុះ នឹកឃើញស្រុកកើតសង្គ្រាមទៀតហើយ លែងបានធ្វើអីលែងបានរកស៊ីអី ពុកម៉ែខ្ញុំចេះតែគិតមិនដឹងទៅរកស៊ីអីបើស្រុករដ្ឋប្រហារហើយ វីវរគេសម្លាប់អស់មួយពូជពង្សតាមមើល ម៉ែពុកខ្ញុំនិយាយ ហើយខ្ញុំចេះតែគិតដែរ បើយើងស្លាប់ទៅ មិនដឹងធ្វើម៉េចបើស្លាប់ទៅហើយ ។

សុវណ្ណៈ	មីងគិតថា អ្វីដែលធ្វើឲ្យមីងអត់បានរៀនសូត្រ អ្វីដែលគោលបំណងមីងធំឡើងចង់ធ្វើពេទ្យ គឺដោយសារមានរដ្ឋប្រហារ?

ហេនៈ	ចា៎! រដ្ឋប្រហារទៅក៏លែងបាន អ្នកណាៗក៏លែងបានរៀនទាំងអស់គ្រប់គ្នា ។

សុវណ្ណៈ	ហើយមីងយល់ ថារដ្ឋប្រហារពេលហ្នឹងយ៉ាងម៉េចដែរ?

ហេនៈ	យល់ថាគេចង់ទម្លាក់ដំណែងសម្តេចឪ ហើយគេចង់ឡើងសោយរាជ្យ ទទួលដំណែងជំនួសសម្តេច នឹកស្មានថាមិនបានសេចក្តីសុខតទៅមុខទៀតទេ គេឡើងទទួលដំណែងថ្មីនឹកឃើញថាអីចឹង ។

សុវណ្ណៈ	កាលហ្នឹងគេធ្វើរដ្ឋប្រហារឆ្នាំណា?

ហេនៈ	ឆ្នាំ៧០ ។

សុវណ្ណៈ	អ្នកណាអ្នកធ្វើរដ្ឋប្រហារ?

ហេនៈ	លន់ នល់ ។

សុវណ្ណៈ	ហើយមីងដឹងថ្ងៃទីប៉ុន្មាន ខែប៉ុន្មាន?

ហេនៈ	អត់ដឹង ភ្លេចបាត់អស់ហើយ ។

សុវណ្ណៈ	មិនមែនថ្ងៃ១៨ ខែមិនាទេ?

ហេនៈ	ដឹងអីបើខ្ញុំភ្លេចអស់ហើយ ។

សុវណ្ណៈ	មីងពេលរដ្ឋប្រហារភ្លាមសភាពការណ៍នៅក្នុងភូមិមីងយ៉ាងម៉េចដែរ?

ហេនៈ	ចលាចលគ្រប់គ្នា ។

សុវណ្ណៈ	គេចលាចលរបៀបម៉េច?

ហេនៈ	ចលាចលខ្លះគេចង់ទៅស្រុកកំណើតគេវិញ ខ្លះក៏ចង់ទៅនៅស្រុកផ្សេងឆ្ងាយពីគ្នា តែខ្ញុំអត់មានចិត្តចង់ទៅណាទេ ចង់ទៅនៅស្រុកណាទៀតទេ មកនៅស្រុកព្រៃ បើគេរកម៉េចៗក៏នាំគ្នាពួនក្នុងព្រៃ ។

សុវណ្ណៈ	មុនឆ្នាំ៧០ ខ្ញុំចង់និយាយថាមុនរដ្ឋប្រហារ មុនគេអត់ទាន់មានរដ្ឋប្រហារ សភាពការណ៍នៅក្នុងភូមិមីងយ៉ាងម៉េចដែរពេលហ្នឹង?

ហេនៈ	កាលហ្នឹងពីមុនរដ្ឋប្រហារអត់មានសភាពការណ៍អីទេ ធម្មតាៗនាំគ្នាធ្វើស្រែចំការធម្មតា ។

សុវណ្ណៈ	តែគេមានខាងទាហាន ខាងវៀតណាម ខាងយៀកកុងគេចូលមកក្នុងភូមិ?

ហេនៈ	អត់ទាន់មានទេកាលហ្នឹង អត់ទាន់មានដូចថាខាងរដ្ឋប្រហារហើយប្រឹបបានជាប៉ុន្មានខែ ២-៣ខែអីចឹងទៅបានមានវៀតណាមគេចូលមកនៅតាមភូមិ គ្រប់ភូមិក៏ខ្មែរយើងចូលរួមនៅជាមួយគេ ធ្វើបដិវត្តន៍គេហៅបដិវត្តន៍ ។

សុវណ្ណៈ	កាលហ្នឹងមីងចូលបដិវត្តន៍ឆ្នាំណាកាលហ្នឹង?

ហេនៈ	ខ្ញុំចូលតាំងពីឆ្នាំ៧២ ។

សុវណ្ណៈ	កាលហ្នឹងមូលហេតុអីមីងចូលបដិវត្តន៍?

ហេនៈ	ចូលទៅកាលហ្នឹងនៅភូមិធ្វើឈ្លបភូមិ ចូលជាឈ្លបភូមិហើយបានខ្ញុំលះបង់ចូលទៅនៅអង្គភាព ។

សុវណ្ណៈ	ប៉ុន្តែខ្ញុំចង់សួរថាមូលហេតុអីបានជំរុញឲ្យមីងចង់ចូលរួមធ្វើបដិវត្តន៍ជាមួយគេ?

ហេនៈ	មូលហេតុដូចថាឃើញគេទៅធ្វើដើម្បីរំដោះជាតិ ចេះតែចង់ធ្វើនឹងគេដើម្បីទៅតស៊ូជាមួយគេ ដូចថាមានគំនិតមួយទៅគេម៉េច យើងម៉េច គេហៅថាចូលព្រៃម៉ាគីកាលហ្នឹង ។

សុវណ្ណៈ	អ្នកណាគេថាកាលហ្នឹង?

ហេនៈ	មេដឹកនាំ មេក្រោមៗចេះតែថាអីចឹងទៅ ។

សុវណ្ណៈ	អីចឹងយើងចូលរួមបដិវត្តន៍ជាមួយគេ ចេះតែចូលតាមគេទេ?

ហេនៈ	ចាំ! ចេះតែចូលទៅ គេថារំដោះជាតិក៏រំដោះជាតិនឹងគេទៅ ។

សុវណ្ណៈ	ប៉ុន្តែក្នុងចិត្តមីងយល់ឃើញយ៉ាងម៉េចបានចូលរួមជាមួយគេ?

ហេនៈ	យល់ដូចថាចង់ធ្វើនឹងគេទៅ គេរំដោះក៏រំដោះនឹងគេទៅ បើថាគេមិនរំដោះចេះតែតស៊ូទៀតចេះតែទៅទៀត ។

សុវណ្ណៈ	តែក្នុងចិត្តរបស់មីងចូលរួមដើម្បីជួយអ្នកគេ? ដើម្បីប្រទេសជាតិ?

ហេនៈ	ខ្ញុំយល់ ដូចចង់ថារំដោះសម្តេចឪមកវិញ ក្នុងអារម្មណ៍យើង ក្នុងគំនិតរបស់យើងគិតថារំដោះយកសម្តេចឪមកវិញ ទាមទារយកសម្តេចឪមកវិញ អីចឹងបានគេថាទៅរំដោះក៏ទៅរំដោះសម្តេចឪ ទាមទារយកសម្តេចឪមកវិញ ។

សុវណ្ណៈ	ដល់ពេលចូលទៅជាមួយគេ មីងគិតថាខ្លួនឯងបានទាមទារ ជួយសម្តេចឪត្រឡប់មកវិញទេ?

ហេនៈ	គិតដែរ គិតថាយូរៗទៅ ដល់ដឹងពីច្បាប់ទម្លាប់ គេធ្វើដើម្បីខ្លួនគេ នឹកឃើញចិត្តខ្លួនឯងតែមិនហ៊ានចេញស្តីថាគេធ្វើដើម្បីគំនិតរបស់គេ បុគ្គលគេ ខ្ញុំគិតឃើញអីចឹងដល់យូរទៅៗវាមានបែកជាគំនិតតូចៗមួយគិតថា គេតស៊ូយូរៗទៅដើម្បីរបស់គេ បុគ្គលគេតាំ នាំគ្នាគិតគ្នាឯង តែមិនហ៊ានបញ្ចេញជារូបភាពឲ្យគេដឹង ឲ្យគេយល់ទេ ។

សុវណ្ណៈ	ដល់ពេលយើងដឹងអីចឹងហើយយើងគិតម៉េច យើងចង់ដកខ្លួនទៅវិញ ឬក៏យើងធ្វើយ៉ាងម៉េច?

ហេនៈ ដល់ពេលចូលមកធ្វើជាទ័ពនារីនៅនឹងមជ្ឈិមនៅភូមិភាគ ក៏នឹកឃើញស្មានថាមកចូលវិទាហានរំដោះប្រទេស រំដោះស្រុក ចូលនៅធ្វើទ័ពនារីនឹងគេ ក៏ចូលមក មករៀនសូត្រនឹងគេឯង រៀនពីច្បាប់ រៀនពីនយោបាយ រៀននិងស្តាប់វិភាគយូរៗទៅក៏នឹកឃើញថាមកហើយរំដោះភ្នំពេញ ។

សុវណ្ណៈ មីងកុំអាលដល់ហ្នឹង ខ្ញុំចង់ឲ្យច្បាស់កន្លែងនេះបន្តិចខ្ញុំអត់ច្បាស់ ខ្ញុំចង់សួរថា ពេលដែលមីងចូលបដិវត្តន៍ពីណានាំចូល?

ហេនៈ កាលហ្នឹងអត់មានពីណានាំខ្ញុំចូលទេ ខ្ញុំនឹកឃើញខ្ញុំចង់ទៅខ្លួនឯង ។

សុវណ្ណៈ យើងចង់ទៅកើតដែរ អត់មានពីណានាំផ្លូវយើង ណែនាំយើង?

ហេនៈ អ្នកនាំផ្លូវគឺគេអ្នកភូមិហ្នឹងគេឃោសនា ដូចថាអ្នកដឹកនាំមេឈ្លប គេមកអប់រំប្រជុំយើងហៅយើងទៅប្រជុំរហូត ប្រជុំរាល់ថ្ងៃ នយោបាយ ប្រជុំពីសីលធម៌ ម្យ៉ាងគេចង់ដឹងពីសីលធម៌យើងកែប្រែខ្លួនយើង សីលធម៌ល្អ ចរិតល្អ អាកប្បកិរិយាល្អ ចង់ឲ្យដូចគេក៏សំរេចថាចូលធ្វើនឹងគេទៅ ។

សុវណ្ណៈ តែគេអត់មានណែនាំយើងទេ?

ហេនៈ ចាំ!

សុវណ្ណៈ អីចឹងខាងនោះគេមកអូសទាញយើងចូលរួមជាមួយគេទៅ?

ហេនៈ ចាំ!

សុវណ្ណៈ អូសទាញគេប្រើលក្ខណៈជាការឃោសនា ឬគេប្រើលក្ខណៈយ៉ាងម៉េចមីង គេមកអូសទាញយើងចូលរួម?

ហេនៈ គេអត់ឃោសនាទេ ដូចថាគេមកប្រជុំអីចឹង ស្រេចតែយើងយល់ទេ យើងចូលក៏ចូល បើយើងមិនចូលក៏ហីទៅគេក៏មិនបង្ខំយើងដែរ តែបើយើងមានគំនិតមួយលះបង់សាច់ឈាមយើងដើម្បីប្រទេសជាតិហ្នឹងយើងចូលទៅ បើយើងមិនលះបង់ទេយើងនៅជាប្រជាជនក៏បាន ដល់ខ្ញុំនឹកឃើញថាគេមិនបង្ខំយើងអីចឹង ក៏នឹកឃើញថាគេចូលគេនារីៗ យុទ្ធជនអីគេចូលអស់ គ្មាននារី គ្មានយុទ្ធជននៅក្នុងភូមិ នៅតែ២-៣នាក់ ដល់អីចឹងក៏សំរេចចូលទៅនឹងគេ ចូលទៅតស៊ូនឹងគេ២ឆ្នាំ ។

សុវណ្ណៈ ចូលដំបូងគេឲ្យធ្វើអីគេ? កាលមីងចូលរួមជាមួយគេដំបូង? ចូលបដិវត្តន៍?

ហេនៈ ចូលដំបូងខ្ញុំអ្នកនាំនីរសា នាំសំបុត្រទៅឲ្យភូមិមួយទៅភូមិមួយ ។

សុវណ្ណៈ ដំបូងគេឲ្យមីងធ្វើនីរសា?

ហេនៈ ចាំ! ធ្វើនីរសា ។

សុវណ្ណៈ	នីរសាឲ្យអ្នកណា?
ហេនៈ	នីរសាឲ្យក្នុងសង្កាត់ ភូមិខ្ញុំហ្នឹងឯង។
សុវណ្ណៈ	តែអ្នកដែលមីងត្រូវធ្វើការងាររត់សំបុត្រឲ្យគាត់ អ្នកគ្រប់គ្រងមីងពីណាគេពេលហ្នឹង?
ហេនៈ	អ្នកលើធំជាងគេគឺស្រុក យកទៅឲ្យសំបុត្រ យកជូនទៅស្រុក។
សុវណ្ណៈ	តែមីងនៅក្រោមការគ្រប់គ្រងរបស់ពីណាគេ? នីរសាហ្នឹង?
ហេនៈ	នីរសានៅគ្រប់គ្រងក្នុង។
សុវណ្ណៈ	ពីណាគេអ្នកគ្រប់គ្រងរបស់មីង?
ហេនៈ	ឈ្មោះអីគេភ្លេចបាត់ហើយ យូរហើយ អត់ចាប់អារម្មណ៍។
សុវណ្ណៈ	តែស្រី ឬប្រុសកាលហ្នឹង?
ហេនៈ	ប្រុស។
សុវណ្ណៈ	អីចឹងការងារដំបូងធ្វើនីរសាទេ?
ហេនៈ	ចាំ!
សុវណ្ណៈ	ធ្វើនីរសារហើយធ្វើអីទៀតកាលហ្នឹង?
ហេនៈ	ធ្វើនីរសារហើយដំបូងបានខ្ញុំដកខ្លួនខ្ញុំឈប់ធ្វើឈ្លបហ្នឹង ខ្ញុំឈប់ធ្វើនីរសារ ខ្ញុំមកនៅជាប្រជាជនធម្មតាវិញ ហើយក៏ខ្ញុំមានស្រុកដូចថា ក្នុងក្រសួងស្រុកគេមកធ្វើការ ធ្វើស្រែក្នុងភូមិខ្ញុំ ខ្ញុំឃើញគេមកសំរាកនៅក្នុងភូមិខ្ញុំ ដល់គេមកធ្វើគេមកហៅ គេមកនាំថាប្អូនទៅនៅអង្គភាពជាមួយខ្ញុំទៅ ខ្ញុំអត់ហ៊ានទៅទេចាំខ្ញុំសួរឪម៉ែខ្ញុំសិន ខ្ញុំថាអីចឹង។ ខ្ញុំសួរឪម៉ែខ្ញុំ ម៉ែខ្ញុំអត់ឲ្យទៅទេ អត់ឲ្យធ្វើ ក៏ម្ដងជាពីរដង គេមកឃោសនា មកហៅម៉ែខ្ញុំទៅទៀត ម៉ែខ្ញុំក៏ទៅខ្ញុំក៏ទៅ ទៅទាំងអស់គ្នាមួយគ្រួសារ ទៅធ្វើបដិវត្តន៍ ចូលទៅនៅអង្គភាពដូចជាធ្វើស្រែគេហៅផលិតខាងក្រសួងផលិត។
សុវណ្ណៈ	ផលិតអីគេមីង?
ហេនៈ	ផលិតដូចថា ផលិតអីក៏បាន ដូចជាធ្វើស្រូវ ធ្វើជាសណ្ដែក ល្ង។
សុវណ្ណៈ	មីងធ្វើនីរសារធ្វើបានប៉ុន្មានឆ្នាំ?
ហេនៈ	ខ្ញុំធ្វើបានប៉ុន្មានខែទេ កាលហ្នឹង២ឬក៏៣ខែ។
សុវណ្ណៈ	ម៉េចគេឲ្យយើងឈប់បាន?
ហេនៈ	ខ្ញុំសុំគេឈប់។
សុវណ្ណៈ	ពេលសុំគេថាម៉េចទៅ?
ហេនៈ	គេអត់មានថាម៉េច គេឲ្យយើងឈប់ក៏បាន។

សុវណ្ណៈ ឈប់តែយើងនៅតែចូលរួមបដិវត្តន៍ជាមួយគេដដែល?

ហេនៈ ចាំ!

សុវណ្ណៈ គ្រាន់តែយើងឈប់ធ្វើជានីរសារ យើងមកធ្វើជាប្រជាជនសិន?

ហេនៈ ចាំ!

សុវណ្ណៈ ចូលបដិវត្តន៍ដំបូងកាលហ្នឹងមីងចូលម្នាក់ឯង ឬក៏ចូលជាមួយឪពុកម្ដាយ?

ហេនៈ ម្នាក់ឯងទេដំបូង ។

សុវណ្ណៈ ដល់ក្រោយមកយើងចេញពីធ្វើនីរសា យើងមករស់នៅភូមិស្រុកកំណើតវិញ?

ហេនៈ ចាំ!

សុវណ្ណៈ ត្រឡប់មកផ្ទះនៅវិញ?

ហេនៈ មកនៅផ្ទះវិញ ។

សុវណ្ណៈ គេអត់មានថាអីឲ្យយើង?

ហេនៈ អត់ថាអីទេ ។

សុវណ្ណៈ យើងចូលហើយចេញមកវិញ?

ហេនៈ គេអត់ថាអី ។

សុវណ្ណៈ កាលហ្នឹងយើងប្រាប់គេថាម៉េចបានយើងចេញបាន?

ហេនៈ គ្រាន់តែយើងសុំគេថាមកជួយធ្វើការងារម៉ែឪក្រ មកជួយធ្វើការងារ ដល់អីចឹងគេឲ្យយើង សំរាក បានកន្លះឆ្នាំ បានដាច់៧២គេមកធ្វើការ គេស្គាល់ ។

សុវណ្ណៈ កាលមីងចូលដំបូង៧២ហ្នឹងនៅដើមឆ្នាំ៧២ ពាក់កណ្ដាល៧២ ឬចុង៧២?

ហេនៈ ដើម ។

សុវណ្ណៈ ដល់ធ្វើបាន២-៣ខែក៏ឈប់ត្រឡប់មកវិញ ដល់ខ្ទង់ចុង៧២គេមកតាមម្ដងទៀត?

ហេនៈ អាចូលឈ្លប ធ្វើនីរសារខ្ញុំចូលធ្វើតាំងពីឆ្នាំ៧១ ។

សុវណ្ណៈ អីចឹងនីរសារ៧១ទេ?

ហេនៈ ចាំ!

សុវណ្ណៈ ៧១ហ្នឹងពេលណា ចុង ដើម ឬកណ្ដាល៧១ ចូលដំបូង?

ហេនៈ កណ្ដាលហើយ កណ្ដាលឆ្នាំ អាចខែគេធ្វើស្រែ ចំការ ខែពិសាខ ជេស ។

សុវណ្ណៈ ខែ៥-៦?

ហេនៈ ខែ៥-៦ហើយ ។

សុវណ្ណៈ អីចឹងពាក់កណ្ដាលហើយ ។

ហេនៈ ចា៎! ពាក់កណ្តាលហើយ ។

សុវណ្ណៈ ពាក់កណ្តាលចូលបដិវត្តន៍ដំបូង?

ហេនៈ ចា៎!

សុវណ្ណៈ ធ្វើនីរសារ?

ហេនៈ ចា៎!

សុវណ្ណៈ បាន២-៣ខែ?

ហេនៈ ចា៎!

សុវណ្ណៈ ដល់ធ្វើហើយត្រឡប់មកផ្ទះវិញ?

ហេនៈ ចា៎! ត្រឡប់មកផ្ទះវិញសំរាក ។

សុវណ្ណៈ បានមួយរយៈ?

ហេនៈ ចា៎! បានមួយរយៈ ។

សុវណ្ណៈ ពេលណាបានគេមកតាមម្តងទៀត?

ហេនៈ គេអត់តាមទេ គេមកធ្វើការនៅនឹងភូមិខ្ញុំហ្នឹង គេបបួលពុកម៉ែខ្ញុំ គេថាពួងឯងទៅៗជាមួយពួកខ្ញុំធ្វើនង្គ័ល រនាស់ឲ្យគេភ្ជួរ ធ្វើស្រែ ក៏ឪខ្ញុំទៅ បបួលម៉ែទៅ ម៉ែចូលទៅដល់គេឲ្យនៅមួយកន្លែងធ្វើរនាស់ នង្គ័ល ឲ្យគេភ្ជួរ ។

សុវណ្ណៈ មីងគេឲ្យធ្វើអីគេ?

ហេនៈ ខ្ញុំទៅជាមួយក្រុមនារី ទៅនៅជាមួយក្រុមនារី ទៅស្ទូង ដក ។

សុវណ្ណៈ ដល់ពេលចូលម្តងទៀតចិតប៉ុន្មាន ៧២ ឬ៧១?

ហេនៈ ៧២ ។

សុវណ្ណៈ ៧២ខ្ទង់ខែណាចូលម្តងទៀត?

ហេនៈ ៧២ខែ១ ។

សុវណ្ណៈ ដើមឆ្នាំ៧២?

ហេនៈ ចា៎! ដើមឆ្នាំ៧២ ។

សុវណ្ណៈ ចូលទៅដល់ ចូលក្រុមនារី?

ហេនៈ ចូលក្រុមនារី ។

សុវណ្ណៈ ចូលក្រុមនារីគេឲ្យធ្វើអីគេពេលហ្នឹង?

ហេនៈ អត់មានធ្វើអីទេ ធ្វើជាសមាជិកគេទេ ចូលជាសមាជិក ធ្វើក្រុម គេឲ្យជំរាស់ស្មៅ ដកស្ទូងហ្នឹងឯង អត់មានធ្វើអីទេ ។

សុវណ្ណៈ ខ្ញុំចង់និយាយថាការងារប្រចាំថ្ងៃធ្វើអីខ្លះ?

ហេនៈ ការងារប្រចាំថ្ងៃធ្វើដូចថា ធ្វើស្រែ ដកស្មៅ ដកស្ទូង តែប៉ុណ្ណឹងឯង ដាំសណ្ដែក ដកស្មៅព្រៃ ។

សុវណ្ណៈ អ្នកណាគេអ្នកគ្រប់គ្រងក្រុមនារីហ្នឹង?

ហេនៈ កាលហ្នឹងច្រើនគ្នាដែរ ។

សុវណ្ណៈ តែដឹបូងឈ្មោះអីគេ?

ហេនៈ ដឹបូងគេបង្អស់ឈ្មោះ ឆាង ។

សុវណ្ណៈ ឈ្មោះ ឆាង ឬម៉េច?

ហេនៈ ឆាង ។

សុវណ្ណៈ ក្មេងជាងមីង ឬចាស់ជាងមីងពេលហ្នឹង?

ហេនៈ គេចាស់ហើយ គេមានកូន១-២ហើយ ។

សុវណ្ណៈ អីចឹងបងឆាង?

ហេនៈ ចា៎! បងឆាង ។

សុវណ្ណៈ ស្រីឬប្រុសកាលហ្នឹង?

ហេនៈ ប្រុស ។

សុវណ្ណៈ ក្រុមនារីម៉េចប្រុសគ្រប់គ្រងវិញ?

ហេនៈ ទេហ្នឹងមេរួមគេ កាន់មួយមន្ទីរហ្នឹង ។

សុវណ្ណៈ កាលហ្នឹងមន្ទីរអីគេ ក្រុមនារីហ្នឹង?

ហេនៈ មន្ទីរផលិត ។

សុវណ្ណៈ មានលេខទេ? លេខប៉ុន្មានអីប៉ុន្មាន?

ហេនៈ អត់មានលេខទេ ។

សុវណ្ណៈ នៅស្រុកមីងគេហៅតំបន់អីគេកាលហ្នឹង? តំបន់ប៉ុន្មានមានលេខទេ?

ហេនៈ តំបន់ភូមិភាគអីទេ ភូមិភាគ៤ទេដឹង ខ្ញុំភ្លេចហើយយូរហើយ ។

សុវណ្ណៈ តែនៅក្នុងស្រុករលាប្អៀរដែលទេ?

ហេនៈ អត់ទេ ខ្ញុំនៅខាងកំពង់ចាម ។

សុវណ្ណៈ ដល់ពេលចូលបដិវត្តន៍មីងមកខាងណាវិញ?

ហេនៈ មកខាងកំពង់ចាមនេះវិញ ។

សុវណ្ណៈ មកខាងកំពង់ចាមវិញទេ?

ហេនៈ ចា៎!

សុវណ្ណៈ មកខាងភូមិភាគបូព៌ាហ្នឹង?

ហេនៈ ហ្នឹងហើយភូមិភាគបូព៌ា ។

សុវណ្ណៈ ដល់ពេលចូលបដិវត្តន៍ចេញពីកំពង់ឆ្នាំងមកកំពង់ចាម?

ហេនៈ ខ្ញុំចេញពីស្រុកខ្ញុំមកតាំងពីជំនាន់៦៧-៦៨ តាំងខ្ញុំនៅតូចៗកូនង៉ាម៉ែខ្ញុំមក ដល់ខ្ញុំធំដឹងក្ដីខ្ញុំនៅក្នុងបូព៌ាហ្នឹងឯង ។

សុវណ្ណៈ កាលមីងកើតនៅខាងរលាប្អៀរហ្នឹងទេ?

ហេនៈ នៅកំពង់ឆ្នាំង ។

សុវណ្ណៈ ដល់ក្រោយមករើមកនៅខាងកំពង់ចាម?

ហេនៈ ខ្ញុំនៅខាងកំពង់ចាមនេះវិញ ។

សុវណ្ណៈ កាលហ្នឹងម៉េចរើមកនៅកំពង់ចាមវិញ?

ហេនៈ ម៉ែឪខ្ញុំ ខាងលោកកុងស្ស៊ីអំពាវនាវហៅរកអ្នកជាងធ្វើផ្ទះ ក៏យកពុកខ្ញុំមក ពូខ្ញុំ អ៊ំខ្ញុំបងប្អូនខ្ញុំមកនៅខាងបូព៌ាហ្នឹងមកធ្វើផ្ទះឲ្យកម្មករចំការកៅស៊ូគេនៅ មកឲ្យនៅ ដល់អ៊ីចឹងគេយក៦-៧គ្រួសារមកនៅខាងចំការកៅស៊ូតាបាវ មកនៅហ្នឹងរហូតដល់ខ្ញុំធំដឹងក្ដីរហូតដល់រដ្ឋប្រហារ ។

សុវណ្ណៈ មីងកុំអាលចេះកាលហ្នឹងមីងចេញពីកំពង់ឆ្នាំងឆ្នាំ៦៧ឬ៦៨?

ហេនៈ ខ្ញុំចេញមកតាំងពីនៅតូច ។

សុវណ្ណៈ ដែលឪពុកម្ដាយមីងផ្លាស់មកនៅកំពង់ចាម?

ហេនៈ ហ្នឹងហើយ ។

សុវណ្ណៈ ឆ្នាំ៦៧មីង?

ហេនៈ ឆ្នាំ៦៦-៦៧ហ្នឹងឯងខ្ញុំចេញមក ។

សុវណ្ណៈ ចេញមកដោយសារថាគេត្រូវការជាងធ្វើផ្ទះ?

ហេនៈ ចា៎!

សុវណ្ណៈ អ៊ីចឹងឪពុកម្ដាយមីងក៏មកនៅហ្នឹងទៅ?

ហេនៈ ក៏មកនៅហ្នឹង ។

សុវណ្ណៈ នៅកំពង់ចាមនៅម្ដុំណាកាលហ្នឹង? នៅស្រុកណា?

ហេនៈ ខ្ញុំនៅស្រុកក្រូចឆ្មារ ។

សុវណ្ណៈ ហើយមកដល់ហ្នឹងឪពុកម្ដាយមីងធ្វើអីគេ?

ហេនៈ កាលហ្នឹងធ្វើស្រែ ចំការដូចគ្នា ។

សុវណ្ណៈ គ្រាន់ថាធ្វើជាង?

ហេនៈ ហ្នឹងហើយ ធ្វើជាង ។

សុវណ្ណៈ ជាងធ្វើអីគេ?

ហេនៈ ជាងធ្វើផ្ទះ ។

សុវណ្ណៈ កាលហ្នឹងអ្នកណាគេអ្នកហៅមកធ្វើ?

ហេនៈ លោកភូឈូយ ។

សុវណ្ណៈ ភូឈូយឈ្មោះអីគេ?

ហេនៈ មិនដឹងភូឈូយឈ្មោះអី ហៅលោកភូឈូយៗ ហើយលោកតាកុងសី គេហៅកុងសីតែម្ដង អត់ដឹងឈ្មោះអីទេ អត់ស្គាល់ឈ្មោះ ។

សុវណ្ណៈ គេឲ្យមកធ្វើហ្នឹងទៅ?

ហេនៈ ចា៎! ហៅមកធ្វើ ។

សុវណ្ណៈ ហើយនៅកំពង់ចាមជាប់រហូតទៅ?

ហេនៈ នៅរហូត ។

សុវណ្ណៈ ដល់ពេលក្រោយមកចូលបដិវត្តន៍នៅកំពង់ចាមទេ?

ហេនៈ ចា៎! ចូលបដិវត្តន៍នៅកំពង់ចាម ។

សុវណ្ណៈ នៅខាងស្រុកក្រូចឆ្មារ?

ហេនៈ ចា៎!

សុវណ្ណៈ ចូលបដិវត្តន៍នៅក្រូចឆ្មារដែរ?

ហេនៈ ចា៎!

សុវណ្ណៈ ឆ្នាំ៧១ហ្នឹង?

ហេនៈ ហ្នឹងហើយ ។

សុវណ្ណៈ ខ្ញុំយល់ហើយមិញស្មានតែមីងចូលនៅខាងស្រុករលាប្អៀរ តាមពិតមិនមែនទេ ស្រុករលាប្អៀរស្រុកកំណើតកើតទេ ក្រោយមកយើងប្ដូរផ្ទះមកនៅ ខាងកំពង់ចាម ហើយកាលហ្នឹងកន្លែងគេបដិវត្តន៍គេនៅម្ដុំណា យើងចូលរួមជាមួយគេដំបូងៗ? នៅក្នុងព្រៃ ឬក៏ម៉េច?

ហេនៈ នៅក្នុងភូមិកាលហ្នឹង គេមកនៅក្នុងភូមិ ពួកឈ្លបគេរើសមកនៅក្នុងហ្នឹង ដូចថាក្នុងភូមិដូចយើងអីចឹង ខ្ញុំមានកូនស្រី កូនប្រុស ចូលធ្វើក៏ធ្វើទៅ អ្នកមិនចូលធ្វើក៏ហីទៅ មួយផ្ទះមានចូល២នាក់ ម្នាក់ ។

សុវណ្ណៈ	ដល់ក្រោយមក៧២ចូលម្ដងទៀត ចូលទាំងគ្រួសារតែម្ដង?
ហេនៈ	ចាំ! ចូលទាំងគ្រួសារ ។
សុវណ្ណៈ	ដល់ពេលបងប្អូនផ្សេងៗ គេឲ្យធ្វើអីគេកាលហ្នឹង?
ហេនៈ	បងប្អូនខ្ញុំតូចៗ គេឲ្យទៅរៀន ។
សុវណ្ណៈ	កាលហ្នឹងមីងកូនទីប៉ុន្មាន?
ហេនៈ	ខ្ញុំកូនទី១ ។
សុវណ្ណៈ	មីងបងគេបង្អស់?
ហេនៈ	ចាំ!
សុវណ្ណៈ	ចុះប្អូនផ្សេងៗ នៅតូចៗ គេឲ្យរៀនទេ?
ហេនៈ	នៅប៉ុនៗហ្នឹង ។
សុវណ្ណៈ	មីងនៅក្រុមនារីពេលចូលម្ដងទៀតឆ្នាំ៧២ អ្នកគ្រប់គ្រងធំនៅមន្ទីរហ្នឹងគេឈ្មោះអីគេ?
ហេនៈ	ឈ្មោះ ឆាង ។
សុវណ្ណៈ	តាឆាង?
ហេនៈ	ឈ្មោះតាឆាង ។
សុវណ្ណៈ	ចុះប្រធានក្រុមរបស់មីង?
ហេនៈ	ប្រធាននារីឈ្មោះវណ្ណា គាត់ប្រធានរួមគេ ។
សុវណ្ណៈ	ប្រធាននារីឈ្មោះអីគេមីង?
ហេនៈ	ឈ្មោះវណ្ណា ។
សុវណ្ណៈ	បងវណ្ណា ស្រី ឬប្រុស?
ហេនៈ	ស្រី ។
សុវណ្ណៈ	គេអ្នកគ្រប់គ្រងមីងផ្ទាល់តែម្ដង?
ហេនៈ	ចាំ!
សុវណ្ណៈ	ហើយក្រុមកងនារីរបស់មីងមានគ្នាប៉ុន្មាននាក់?
ហេនៈ	គ្នា៥០នាក់ ទាំងបុរស និងស្ត្រី ។
សុវណ្ណៈ	ច្រើនដែរ ។
ហេនៈ	ហាជាងដង ។
សុវណ្ណៈ	បងវណ្ណា គាត់អ្នកស្រុកណាដែរ?
ហេនៈ	បងវណ្ណា គាត់នៅខាងស្រុកក្រូចឆ្មារ ។

សុវណ្ណៈ	អ្នកនៅហ្នឹងតែម្តង?

ហេនៈ	ចា៎!

សុវណ្ណៈ	ហើយការគ្រប់គ្រងរបស់គាត់យ៉ាងម៉េចដែរពេលហ្នឹង? តឹងរឹង មិនតឹងរឹងទេ?

ហេនៈ	អត់តឹងទេ ល្មម យើងធ្វើអីបាន អត់មានលំបាក ។

សុវណ្ណៈ	ក្រៅពីកិច្ចការដែលគេចាត់ឲ្យយើងធ្វើ ក្នុងក្រុមកងនារីយើងធ្វើអីគេ?

ហេនៈ	អត់មានធ្វើអីទៀតទេ មានតែប៉ុណ្ណឹង ធ្វើចំការ ធ្វើស្រែ ។

សុវណ្ណៈ	ចុះមីងថាទៅវ៉ៃនៅភ្នំពេញ? ចូលទ័ពឆ្នាំណាកាលហ្នឹង?

ហេនៈ	គេជ្រើសរើសហ្នឹងមកខ្ញុំក៏សំរេចសុំម៉ែ សុំអង្គភាពចូលទៅធ្វើទ័ពគេរើសគ្នា២០នាក់ជាង ២៥នាក់ធ្វើទ័ពនារី ។

សុវណ្ណៈ	មីងចូលទ័ព៧៣ ចូលទ័ពនារីហ្នឹង?

ហេនៈ	ចា៎!

សុវណ្ណៈ	អីចឹងបន្ទាប់ពីធ្វើខាងនារី ក្រោយមកចូលទ័ពភ្លាមតែម្តង?

ហេនៈ	ចា៎! ចូលទ័ព ។

សុវណ្ណៈ	៧៣ហ្នឹងចូលខែណាចាំទេ?

ហេនៈ	ចូលកាលហ្នឹងចូលខែ៣ តែមិនដឹងថ្ងៃប៉ុន្មាន ។

សុវណ្ណៈ	ទ័ពនារីហ្នឹងគេរើសលក្ខណៈរបៀបម៉េចបានគេឲ្យយើងចូលបាន?

ហេនៈ	គេរើសយើងស្ម័គ្រចិត្តផង ហើយគេរើសតាមសមត្ថភាពយើងអាចធ្វើបាន យើងប្តេជ្ញាថា យើងដាច់ខាតយើងតស៊ូយើងទៅ ។

សុវណ្ណៈ	គេមានបង្ហាត់បង្រៀនយើងទេមីង?

ហេនៈ	បង្ហាត់ ។

សុវណ្ណៈ	គេបង្ហាត់អីខ្លះ?

ហេនៈ	បង្ហាត់យុទ្ធសាស្ត្រ បង្ហាត់បង្រៀនយើង ហាត់វ៉ៃ បាញ់ រៀនដោះកាំភ្លើង ហាត់លូន ហាត់ដោះមីន ដោះគ្រាប់គ្រប់បែបយ៉ាង ។

សុវណ្ណៈ	ហាត់ប៉ុន្មានខែបានគេឲ្យយើងទៅវ៉ៃបាញ់?

ហេនៈ	ហាត់៣ខែ នយោបាយ៣ខែ ៦ខែទាំងអស់ ។

សុវណ្ណៈ	ហាត់នយោបាយ៣ខែ?

ហេនៈ	ចា៎!

សុវណ្ណៈ	ហាត់នយោបាយអីគេខ្លះ?

ហេនៈ	នយោបាយពីយើងគេដឹកនាំយើងឲ្យយើងធ្វើការដាច់ខាត ពីរបៀបសីលធម៌ វប្បធម៌ខ្មែរយើងយ៉ាងណាៗទៅមុខទៀត សីលធម៌យើង១២ប្រការមានអីខ្លះ ។

សុវណ្ណៈ	ហើយមីងចាំសីលធម៌១២ប្រការហ្នឹងទេ មានអីគេខ្លះ?

ហេនៈ	អត់ចាំអស់ទេ ភ្លេចអស់ហើយ ។

សុវណ្ណៈ	ហាត់ដោះមីន ហាត់បាញ់កាំភ្លើង ហាត់ក្រាប ហាត់ទាហានហាត់អីគេខ្លះ?

ហេនៈ	ហាត់លូនចូលបន្ទាយ លូនកាត់ខ្សែលួសរបង ដាក់មីន ចូលទៅវៃផ្កាវីក ។

សុវណ្ណៈ	កាលហ្នឹងមូលហេតុអីយើងសំរេចចូលទ័ពមីង?

ហេនៈ	មូលហេតុយើងចង់ ឃើញគេទៅម្យ៉ាងអារម្មណ៍គិតខ្លះ មានអារម្មណ៍មួយចង់សប្បាយអារម្មណ៍មួយចង់តស៊ូ ដើម្បីរំដោះប្រទេសជាតិ នឹកឃើញអីចឹង ។

សុវណ្ណៈ	ចង់សប្បាយហ្នឹងចង់សប្បាយម៉េច?

ហេនៈ	ចង់សប្បាយឃើញគេបាញ់គ្នាមើលទៅមានអារម្មណ៍ថាសប្បាយ នៅក្មេងៗគិតថាសប្បាយ ។

សុវណ្ណៈ	បានកាន់កាំភ្លើង?

ហេនៈ	បានកាន់កាំភ្លើងទៅដូចថាមានមោទនភាពខ្លួនឯងយើងអ្នកតស៊ូមួយ នឹកឃើញអីចឹង ។

សុវណ្ណៈ	អ្នកណាជាអ្នកគ្រប់គ្រងនៅក្នុងទ័ពនារីហ្នឹង?

ហេនៈ	ទ័ពនារីហ្នឹងឈ្មោះអីទេ ភ្លេចបាត់ហើយ ពីមេកងធំឈ្មោះអីទេភ្លេចបាត់ហើយ នៅចាំតែក្រុម និងមេកងតូច ។

សុវណ្ណៈ	ក្រុមឈ្មោះអីគេ ប្រធានក្រុម?

ហេនៈ	ក្រុមឈ្មោះវាង នារីវាង ។

សុវណ្ណៈ	វាង?

ហេនៈ	ចា៎!

សុវណ្ណៈ	វៀតណាមឬខ្មែរមីង?

ហេនៈ	ខ្មែរ ។

សុវណ្ណៈ	ឈ្មោះដូចវៀតណាមម្ល៉េះ?

ហេនៈ	ហ្នឹងហើយ ។

សុវណ្ណៈ	ហ្នឹងប្រធានក្រុម?

ហេនៈ	ចា៎!

សុវណ្ណៈ	ប្រធានអីមួយទៀត?

ហេនៈ ប្រធានកង ។

សុវណ្ណៈ ប្រធានកងអីគេ?

ហេនៈ ប្រធានកងតូច គេហៅប្រធានខ ឈ្មោះខឿន ទេដឹង ។

សុវណ្ណៈ តែមីងនៅក្រោមការគ្រប់គ្រងរបស់អ្នកណាគេកាលហ្នឹង? ទ័ពនារីហ្នឹង?

ហេនៈ នៅហ្នឹង ។

សុវណ្ណៈ អ្នកគ្រប់គ្រងផ្ទាល់របស់មីង?

ហេនៈ វ៉ាន់ហ្នឹងឯង ។

សុវណ្ណៈ ប្រធានក្រុម?

ហេនៈ ប្រធានក្រុម ។

សុវណ្ណៈ កាលហ្នឹងគេហៅកងអីគេ?

ហេនៈ កងប្រយុទ្ធ ។

សុវណ្ណៈ មានលេខទេ? កងពលលេខប៉ុន្មាន?

ហេនៈ កងពលលេខ៤ ។

សុវណ្ណៈ មីងកងពលលេខ៤?

ហេនៈ ចា៎! គេហៅយ-៤ ។

សុវណ្ណៈ កងពលខ-៤?

ហេនៈ យ-៤ ។

សុវណ្ណៈ អ្នកណាគេប្រធានកងពល?

ហេនៈ ប្រធានកងពលប្រុសទេ ។

សុវណ្ណៈ តែអ្នកណាគេ?

ហេនៈ ភ្លេចឈ្មោះអស់ហើយ យកជាគ្នាមិនបាន ។

សុវណ្ណៈ អ្នកដែលមីងជួបញឹកញាប់ជាងគេ?

ហេនៈ តែវ៉ាន់ ហ្នឹងទេ ។

សុវណ្ណៈ វ៉ាន់ ហ្នឹងស្រី?

ហេនៈ ស្រី ។

សុវណ្ណៈ ម៉េចថាប្រុស?

ហេនៈ វ៉ាន់ ស្រី ។

សុវណ្ណៈ ស្រី ត្រូវហើយ ។ គាត់នៅស្រុកណាវ៉ាន់ ហ្នឹង?

ហេនៈ វ៉ាន់ នៅខាងស្រុកកណ្ដាលជ្រុំ នៅខាងតាបែ មិនដឹងស្រុកអីស្រុកកំណើត ភ្លេចបាត់ ។
សុវណ្ណៈ អត់អីទេ ហើយមីងគេឲ្យកាន់ខាងអីខ្លះ? ឬត្រឹមជាកូនចៅ?
ហេនៈ ខ្ញុំអត់បានធ្វើអីទេ កាន់បានតែពួក ៣នាក់ៗ ។
សុវណ្ណៈ មីងប្រធានពួក?
ហេនៈ ចា៎! ប្រធានពួក ។
សុវណ្ណៈ កាន់ប៉ុន្មាននាក់?
ហេនៈ កាន់ប្រធានពួកម្ដង ។
សុវណ្ណៈ ហើយកងពលគេបែងចែកចេញជាប៉ុន្មានវរសេនា?
ហេនៈ តាមវរៈ មួយយហ្នឹង២វរៈ តែមិនដឹងវរៈប៉ុន្មានៗខ្ញុំភ្លេចអស់ហើយ ។
សុវណ្ណៈ ពេលឡើងទៅដំបូង ឡើវៃខាងណា?
ហេនៈ ឡើងវៃខាងអ្នកលឿង ខាងព្រៃវែង ទៅវៃខាងហ្នឹង ។
សុវណ្ណៈ ទៅវៃខាងអ្នកលឿង ព្រៃវែង?
ហេនៈ ខាងស្វាយ ។
សុវណ្ណៈ អីចឹងមីងកាលមុននៅខាងកើតទន្លេទេ?
ហេនៈ ចា៎!នៅខាងកើតទន្លេ ។
សុវណ្ណៈ កាលយើងនៅក្រូចឆ្មារហ្នឹង?
ហេនៈ ចា៎!
សុវណ្ណៈ ចុះពេលឡើងវៃទៅសមរភូមិដំបូង មីងចេញទៅវៃខាងណា?
ហេនៈ ដំបូងចេញមកវៃស្វាយមុនគេ ។
សុវណ្ណៈ ហើយដល់ពេលវៃហ្នឹងមីងនៅខ្សែត្រៀមណា?
ហេនៈ ថ្នល់ជាតិ ។
សុវណ្ណៈ តែយើងនៅខ្សែមុខ ខ្សែក្រោយ ឬខ្សែជំនួយ?
ហេនៈ ខ្ញុំនៅខាងខ្សែទី២ ។
សុវណ្ណៈ ខ្សែទី២ខ្សែអីគេ?
ហេនៈ ខ្សែខាងទទួលអ្នករបួស យើងទទួលបញ្ជូនទៅក្រោយ ។
សុវណ្ណៈ តែមីងបាញ់ដែលអត់?
ហេនៈ បើខ្សែទី១គេអស់កំលាំង គេឲ្យយើងឡើងទៅម្ដង ។
សុវណ្ណៈ ហើយគេរៀបប៉ុន្មានខ្សែពេលវៃម្ដងៗ?

ហេនៈ	រៀបពាខ្សែ ២ខ្សែម្ដង ។

សុវណ្ណៈ	ពេលឡើងវ៉ៃដំបូងអារម្មណ៍យ៉ាងម៉េច?

ហេនៈ	ពេលដំបូងភ័យណាស់ ភ័យខ្លាចមិនដឹងគេ មិនដឹងយើង ចេះនឹកខ្លាច ដល់ពេលបានផ្ទុះអាវុធនឹងដៃយើងហើយ ដូចថាអត់មានអារម្មណ៍អីទេ គិតតែបាញ់ គេប្រាប់ថាឲ្យយើងបាញ់តែបាញ់ឲ្យមានទិសដៅ យើងឃើញសឹមបាញ់ ដឹងឃើញមិនឃើញ គេដាក់ទាំងអស់គ្នា ចេះតែទៅៗ ។

សុវណ្ណៈ	ក្នុងអំឡុងពេលមីងហាត់រៀនហ្នឹងមានជំនាញការវៀតណាម គេមកជួយបង្ហាត់បង្រៀនទេខាងទ័ព?

ហេនៈ	អត់ទេ ខ្មែរយើងទាំងអស់ ។

សុវណ្ណៈ	គេមានទស្សនកិច្ចរបស់វៀតណាមគេមកលេង?

ហេនៈ	អត់មានទេ ។

សុវណ្ណៈ	អត់ដែរ?

ហេនៈ	អត់ទេ ។

សុវណ្ណៈ	ចេញពីវ៉ៃស្ទួងហ្នឹងហើយទៅវ៉ៃណាទៀត?

ហេនៈ	មកអ្នកលឿង ព្រៃវែង ចេញពីអ្នកលឿងទៅដកមកវិញមកសំរាកបាន១ខែ បានចូលទៅវ៉ៃព្រៃវែងទៀត ។

សុវណ្ណៈ	យើងអត់មានគិតថាខ្លាចរបួសខ្លះ ស្លាប់ខ្លួនខ្លះ មានទេពេលវ៉ៃ?

ហេនៈ	មានបាក់ដែរ បាក់ម្ដងៗ បាក់ភ័យខ្លាចដល់ឃើញគេរបួស ឬក៏ស្លាប់ច្រើនមានអារម្មណ៍តែមានចិត្តមួយថាបើស្លាប់ដោយសារជាតិវាមិនអត់ប្រយោជន៍ដែរ នឹកឃើញអីចឹង ។

សុវណ្ណៈ	កាលហ្នឹងមីងអាយុប៉ុន្មាន? មាឌប៉ុណ្ណា?

ហេនៈ	ខ្ញុំអាយុ១៨ហើយ ។

សុវណ្ណៈ	ធំដែរ?

ហេនៈ	ធំ ។

សុវណ្ណៈ	យើងវ៉ៃរបៀបម៉េច?

ហេនៈ	វ៉ៃតាមខ្សែត្រៀម ចូលវ៉ៃដូចគ្នា ។

សុវណ្ណៈ	គេនៅប្រវែងណាៗ យើងនៅប្រវែងណា?

ហេនៈ	យើងនៅឆ្ងាយ ដូចថានៅបន្ទាយភូមិនោះ យើងនៅនេះទៅដល់ពេលយើងចង់លួនទៅស៊ើបការណ៍គេឲ្យកងស៊ើបការណ៍គេទៅស៊ើបទៅ ស៊ើបដឹងថាកំលាំងវាប៉ុណ្ណេះៗ ដាក់កាំភ្លើងធំ

បែរមុខទៅណា ក៏គេឲ្យកំលាំងយើងរំកិលឡើងទៅទៀត ក្នុងមួយយប់មានរំកិលតែ២-៣ ដង ឡើងរំកិលទៅវ៉ៃ ។

សុវណ្ណៈ	វ៉ៃផុតពីព្រៃវែងហើយឡើងទៅដល់ណាទៀត?

ហេនៈ	មិនដែលវ៉ៃណាទៀត មកហាត់រៀនម្តងទៀត ។

សុវណ្ណៈ	រៀនអីគេមីង?

ហេនៈ	រៀនយុទ្ធសាស្ត្រម្តងទៀត ។

សុវណ្ណៈ	ម៉េចគេឲ្យយើងរៀនម្តងទៀត យើងរៀនហើយតាំ?

ហេនៈ	រៀនហើយតែគេខ្លាចយើងភ្លេចភាំងគេឲ្យរៀនទៀត តែរៀនអត់កំណត់ ពេលយើងទំនេរពីវ៉ៃ ទំនេរពីសំរាក ។

សុវណ្ណៈ	ពេលឆ្នាំ៧៥គេវ៉ៃបែកភ្នំពេញមីងទៅណាវិញ?

ហេនៈ	វ៉ៃបែកភ្នំពេញខ្ញុំនៅខាងហ្នឹងដែរ នៅខាងព្រៃវែង ។

សុវណ្ណៈ	មីងឡើងទៅវ៉ៃនៅភ្នំពេញទេ?

ហេនៈ	អត់បានឡើងវ៉ៃទេ ។

សុវណ្ណៈ	យើងធ្វើម៉េចបានដឹងថាគេវ៉ៃបែកភ្នំពេញ៧៥?

ហេនៈ	ដឹងតាមរយៈមេធំៗ ។

សុវណ្ណៈ	គេប្រាប់ថាម៉េច?

ហេនៈ	គេប្រាប់ថាជ័យជំនះហើយ ក៏គេស្រែកនឹងជ័យឃោសគេទៅរៀន មេកងធំទៅរៀនមកវិញគេប្រាប់ថាជ័យជំនះនៅភ្នំពេញហើយ គេមកធ្វើមេទ្ទិញ ស្រែកជ័យឃោសថាឈ្នះៗ ដឹងថាឈ្នះ ។

សុវណ្ណៈ	បន្ទាប់ពីគេគ្រប់គ្រងបានហើយយើងធ្វើម៉េចទៀត? គេឲ្យយើងធ្វើម៉េចទៀតបន្ទាប់ពី ៧៥?

ហេនៈ	បន្ទាប់ពី៧៥ហើយខ្ញុំរំដោះភ្នំពេញខ្ញុំរៀនបន្តទៀត រៀននយោបាយ គេឲ្យរៀនបន្តទៀត ។

សុវណ្ណៈ	យើងអត់មានផ្លាស់ទៅណាទៀត?

ហេនៈ	អត់មានផ្លាស់ទេ ។

សុវណ្ណៈ	កាលហ្នឹងយើងនៅណា? ពេលវ៉ៃ?

ហេនៈ	ខ្ញុំនៅព្រៃវែង ។

សុវណ្ណៈ	អីចឹងបានន័យថាយើងឈរជើងនៅព្រៃវែង?

ហេនៈ	ចាំ!

សុវណ្ណៈ	ឈរជើងនៅខាងណា?

ហេនៈ	នៅព្រៃវែង នៅភូមិចារ ។

សុវណ្ណៈ	តែនៅស្រុកណា? នៅទីរួមខេត្ត?

ហេនៈ	នៅទីរួមខេត្តមិនដឹងត្រង់ហ្នឹង ។

សុវណ្ណៈ	ឬនៅម្តុំណានៅព្រៃវែងហ្នឹង?

ហេនៈ	អាចនឹងភូមិចារជើង ។

សុវណ្ណៈ	តែព្រៃវែងមីងឡើងទៅវៃខាងអ្នកលឿង?

ហេនៈ	ខ្ញុំទៅវៃអ្នកលឿងម្តង ខ្ញុំទៅព្រៃវែងម្តង ។

សុវណ្ណៈ	ព្រៃវែងមីងឡើងទៅវៃខាងណា?

ហេនៈ	វៃនឹងក្រុងព្រៃវែង ។

សុវណ្ណៈ	ទីរួមខេត្ត ដល់ពេលវៃហើយយើងទៅឈរជើងនៅណា?

ហេនៈ	ឈរជើងដកថយមកនៅខាងភូមិបាធាយ ស្រុកអីទេ ។

សុវណ្ណៈ	នៅក្នុងខេត្តព្រៃវែង ឬខេត្តណា?

ហេនៈ	ក្នុងខេត្តព្រៃវែង ។

សុវណ្ណៈ	បានន័យថាបន្ទាប់ពីវៃបានព្រៃវែង យើងឈរជើងនៅព្រៃវែងទេ អត់ផ្លាស់ទៅណាទេ អត់ផ្លាស់ទៅណាទេ មីងដឹងថានៅស្រុកណាអត់?

ហេនៈ	ស្រុកស្ដីទេ ស្រុកកញ្ជ្រៀច ។

សុវណ្ណៈ	អីចឹងបានន័យថាយើងឈរជើងនៅស្រុកកញ្ជ្រៀច ខេត្តព្រៃវែង?

ហេនៈ	ចា៎! ស្រុកកញ្ជ្រៀចហ្នឹងឯង ។

សុវណ្ណៈ	នៅក្នុង៧៥-៧៩គេឲ្យយើងធ្វើអីខ្លះ? ពេលដែលគេគ្រប់គ្រងបានហើយ បន្ទាប់៧៥ ធ្វើអីទៀត?

ហេនៈ	រំដោះហើយអីចឹងមក ខ្ញុំចេញពីព្រៃវែងខ្ញុំមកនៅភ្នំពេញ ។

សុវណ្ណៈ	ឆ្នាំណាមីងមកនៅភ្នំពេញ?

ហេនៈ	ឆ្នាំ៧៥ហ្នឹងឯង ។

សុវណ្ណៈ	៧៥ដដែល?

ហេនៈ	ចា៎!

សុវណ្ណៈ	គេរំដោះហើយបានប៉ុន្មានខែ?

ហេនៈ	គេរំដោះហើយបានប៉ុន្មានខែទេ ។

សុវណ្ណៈ ព្រោះគេរំដោះបានខែ៤ ថ្ងៃ១៧ មេសា ៧៥ ចុះពេលមីងមកនៅ?

ហេនៈ មកនៅភ្នំពេញខែប៉ុន្មានទេ ខែ១?

សុវណ្ណៈ ខែ១ គេរំដោះបានខែ៤ហ្នឹង រំដោះហើយប៉ុន្មានខែ ប៉ុន្មានសប្តាហ៍ ប៉ុន្មានថ្ងៃបានមីងចូលមកនៅភ្នំពេញ?

ហេនៈ យូរដែល ។

សុវណ្ណៈ ចូលដល់ខែ ឬថ្ងៃទេ?

ហេនៈ ខ្ញុំនៅសំរាកស្រុកគេយូរដែរ ខ្ញុំនៅរៀនបន្តទៀត ។

សុវណ្ណៈ រៀននយោបាយហ្នឹង?

ហេនៈ ចាំ!

សុវណ្ណៈ អ្នកណាគេអ្នកបង្រៀននយោបាយហ្នឹង?

ហេនៈ នយោបាយហ្នឹងឈ្មោះពូអីទេ ។

សុវណ្ណៈ នយោបាយគេរៀន គេអប់រំយ៉ាងម៉េច?

ហេនៈ គេរៀនពន្យល់អប់រំយើងឲ្យយើងមានស្មារតីតស៊ូ ប្រយុទ្ធ កុំឲ្យយើងរេរា ឲ្យយើងប្រឹងប្រែងធ្វើចំពោះការងារអីមួយយើងកុំរុញរា កុំរាថយ ។

សុវណ្ណៈ មានអីទៀតទេ?

ហេនៈ គ្មានស្អីទៀត ។

សុវណ្ណៈ យើងរៀនបានប៉ុន្មានខែបានគេឲ្យយើងឡើងមកភ្នំពេញ?

ហេនៈ រៀនហ្នឹងរៀនផង ជួយធ្វើស្រែប្រជាជនផង កាលហ្នឹងខែ៤ហើយ ដើមឆ្នាំខ្ញុំនៅចូលឆ្នាំអីស្រុកកញ្ច្រៀចនោះ ខ្ញុំមកខែ៤ សំរាកនៅព្រៃវែងហើយគេយកកាណូតខែទឹកឡើង យកកាណូតទៅយកពួកខ្ញុំមកនៅភ្នំពេញធ្វើការរោងចក្រ គេឲ្យខ្ញុំធ្វើការរោងចក្រ ។

សុវណ្ណៈ មីងចាំខែទេ ឡើងមកខែណា?

ហេនៈ អត់ចំណាំទេខែ ។

សុវណ្ណៈ តែពេលណា ពេលទឹកឡើង? អាចថាពាក់កណ្តាលឆ្នាំ៧៥ ឬខ្ទង់ខែ៧-៨?

ហេនៈ អាចខែប៉ុណ្ណឹងឯងព្រោះខែទឹកឡើង ។

សុវណ្ណៈ ដល់ពេលមកហ្នឹងយើងជិះទូកមកទេ?

ហេនៈ ជិះកាណូត ។

សុវណ្ណៈ យើងមកគ្នាប៉ុន្មាននាក់?

ហេនៈ ជិះម្តង២០នាក់-២៥នាក់ ។

សុវណ្ណៈ ហើយពីណាគេអ្នកដឹកនាំយើងមក?

ហេនៈ មិនដឹងពីណាអត់ស្គាល់គេ គេឲ្យកំលាំងទៅយក ទូកទៅយក ។

សុវណ្ណៈ គេថាម៉េចពេលទៅ?

ហេនៈ ទៅយកយើងគេគ្រាន់តែថាកំលាំងគេ កងធំៗគេប្រជុំឲ្យកងណាមកមុន ក្រុមណាមកមុន គេឲ្យក្រុមហ្នឹងមកមុន គេនៅក្រោយៗទៀត មួយថ្ងៃទៅម្តង ។

សុវណ្ណៈ ពេលដែលមីងនៅធ្វើទ័ពហ្នឹង ខាងនារីការហូបចុកលក្ខណៈខ្វះខាត ឬមិនសូវខ្វះខាតទេ?

ហេនៈ អត់ខ្វះទេ ។

សុវណ្ណៈ ហូបប៉ុន្មានពេលមួយថ្ងៃ?

ហេនៈ មួយថ្ងៃពីរពេល ។

សុវណ្ណៈ គេហូបបាយ ឬហូបបបរ?

ហេនៈ ហូបបាយ ។

សុវណ្ណៈ គេតឹងរឹងទេជាមួយយើងកងទ័ព?

ហេនៈ អត់តឹងទេ ។

សុវណ្ណៈ យើងអាចទៅលេងបងប្អូនបានទេ?

ហេនៈ បើសុំគេបានទៅលេងឲ្យទៅ ។

សុវណ្ណៈ តែយើងធ្វើទ័ពនៅជុំជាមួយបងប្អូន ឬនៅដាច់ដោយឡែក?

ហេនៈ ដាច់ដោយឡែក ។

សុវណ្ណៈ មកនៅក្រុមជាមួយយើងមក?

ហេនៈ ចាំ!

សុវណ្ណៈ ហូបរួម ធ្វើការរួម ដេករួម ទាំងអស់គ្នា?

ហេនៈ ហ្នឹងហើយទាំងអស់គ្នា ។

សុវណ្ណៈ ក្នុងអំឡុងពេលហ្នឹងយើងមាននឹកនា នឹករលឹកដល់ឪពុកម្តាយពេលនៅធ្វើទ័ព?

ហេនៈ នឹកដូចគ្នា តែយើងទៅនៅឆ្ងាយខ្ជិលសុំគេមក បើយើងអាចសុំគេបានក៏មកជាមួយគេដែរ ។

សុវណ្ណៈ តែដែលសុំគេទៅលេងផ្ទះទេ?

ហេនៈ អត់ ។

សុវណ្ណៈ ម៉េចអីចឹង?

ហេនៈ នឹកឃើញថាវាឆ្ងាយខ្ជិលសុំគេ ។

សុវណ្ណៈ អត់នឹកឪពុកម្តាយ នឹកផ្ទះ?

ហេនៈ នឹក តែអត់ហ៊ានសុំគេ ។

សុវណ្ណៈ ម៉េចអត់ហ៊ានសុំអីចឹង?

ហេនៈ ខ្លាចគេ ។

សុវណ្ណៈ ខ្លាចគេថាម៉េច?

ហេនៈ មួយសារហ្នឹងគេរិតបន្តឹងហើយ សូម្បីថាយើងមកនៅនេះហើយអត់ឲ្យយើងដើររហេតរហូត

សុវណ្ណៈ ហើយឪពុកម្តាយមីងគាត់ខូចឆ្នាំណាមីងដឹងទេ?

ហេនៈ អត់ដឹង ។

សុវណ្ណៈ តែក្នុងអំឡុង៧៥ហ្នឹង ពី៧៥-៧៩ដឹងថាគាត់នៅរស់?

ហេនៈ ដល់៧៦ដឹងថាគាត់នៅរស់ ។

សុវណ្ណៈ តែយើងដាច់ដំណឹងរវាងឪពុកម្តាយ បងប្អូនតាំងពី៧៦មក?

ហេនៈ ចា៎!

សុវណ្ណៈ យើងដាច់ដំណឹងតាំងពីយើងនៅព្រៃវែង ឬមកនៅភ្នំពេញ?

ហេនៈ នៅភ្នំពេញហើយ ។

សុវណ្ណៈ អីចឹងមីងមកភ្នំពេញខ្ទង់៧៦ដែរ ត្រូវទេ?

ហេនៈ ខ្ញុំមកពី៧៥ ។

សុវណ្ណៈ តែយើងនៅទាក់ទងដឹងដំណឹង?

ហេនៈ ចា៎!

សុវណ្ណៈ ដល់ពេលមកដំបូងយើងធ្វើដំណើរតាមទូក ជិះប៉ុន្មានថ្ងៃ ប៉ុន្មានយប់បានមកដល់?

ហេនៈ ជិះតែប៉ុន្មានម៉ោងមកដល់ ។

សុវណ្ណៈ លឿនដែរ?

ហេនៈ ចា៎!

សុវណ្ណៈ ហើយមកដល់ដំបូងគេឲ្យយើងនៅណា?

ហេនៈ មកដល់ដំបូងនៅផ្ទះសំណាក់បឹងត្របែក ។

សុវណ្ណៈ គេឲ្យយើងនៅបឹងត្របែក?

ហេនៈ ចា៎!

សុវណ្ណៈ នៅប៉ុន្មានថ្ងៃ?

ហេនៈ នៅបឹងត្របែកអាច៣ថ្ងៃ ។

សុវណ្ណៈ មកនៅបឹងត្របែកគេឲ្យយើងធ្វើអីខ្លះ?

ហេនៈ មកនៅសំរាកចាំគេចែកការងារ ។

សុវណ្ណៈ គេមានណែនាំពន្យល់ប្រាប់យើងអីខ្លះទេ?

ហេនៈ ចា៎! គេប្រាប់ ។

សុវណ្ណៈ គេប្រាប់ថាម៉េច?

ហេនៈ ប្រាប់ឲ្យយើងទៅនៅកន្លែងណាមួយហើយសំរបខ្លួនតាមគេ កុំប្រឆាំងគេ តែយើងអ្នកប្រឆាំងគេហើយគេថាយើងអ្នកប្រឆាំង អីចឹងគេប្រាប់ដំណើរទំនងកុំឲ្យប្រឆាំង មិនដែលហ៊ាន ។

សុវណ្ណៈ ក្រោយមកគេឲ្យយើងទៅធ្វើអីវិញ?

ហេនៈ គេឲ្យខ្ញុំទៅធ្វើរោងចក្រតំបាញ គេចែកជាក្រុម ចែកជាកង ទៅនៅគ្រប់អង្គភាព ។

សុវណ្ណៈ រោងចក្រតំបាញ?

ហេនៈ ចា៎!

សុវណ្ណៈ តំបាញអីគេ?

ហេនៈ ខស្សរាហកម្មនៅ ។

សុវណ្ណៈ តែចង់ថាតំបាញឈ្មោះអីគេ? លេខរៀង ។

ហែនៈ គ-៥ ។

សុវណ្ណៈ រោងចក្រតំបាញគ-៥ នៅខាងណាមីង?

ហេនៈ នៅក្បាលថ្នល់ ។

សុវណ្ណៈ ហើយអ្នកណាគេអ្នកគ្រប់គ្រងនៅរោងចក្រហ្នឹង?

ហេនៈ មុនដំបូងភ្លេចឈ្មោះទៀតហើយ ។

សុវណ្ណៈ ហើយក្រោយមកអ្នកណាគេ?

ហេនៈ ក្រោយមកបានបងហឹង ។

សុវណ្ណៈ ប្រុស ឬស្រី?

ហេនៈ ស្រី ។

សុវណ្ណៈ ហើយបងហឹង ហ្នឹងគាត់មកពីខាងណា?

ហេនៈ បងហឹង អត់ដឹងគាត់នៅខាងណា អត់ដឹងគាត់នៅស្រុកណា ។

សុវណ្ណៈ ហើយមានដូរខាងណាទៀតទេ?

ហេនៈ អត់ទេ ។

សុវណ្ណៈ បន្ទាប់ពីអ្នកមុនបងហឹង រហូតទៅ?

ហេន៖ ចា៎!

សុវណ្ណ៖ ហើយការងារក្នុងរោងចក្រតំបាញមីងធ្វើអីគេ?

ហេន៖ យុង ។

សុវណ្ណ៖ បន្ទាប់ពីបងហឹង ហ្នឹងមកបានពូយុង?

ហេន៖ ពូយុង ហើយបានហឹង ។

សុវណ្ណ៖ ពូយុង មុនដំបូង ក្រោយមកបងហឹង?

ហេន៖ ចា៎!

សុវណ្ណ៖ ម៉េចបានគេដូរពូយុង ហ្នឹងចេញ?

ហេន៖ អង្គការដកទៅ ។

សុវណ្ណ៖ ដកទៅឆ្នាំណា?

ហេន៖ ដកទៅឆ្នាំ៧៦ ហ្នឹងឯងអាចដើមឆ្នាំ ។

សុវណ្ណ៖ ពូយុង ហ្នឹងធ្វើខុសអីគេ?

ហេន៖ អត់ដឹង ។

សុវណ្ណ៖ ហើយពូយុង មកពីខាងណា?

ហេន៖ ពូយុង លឺថានៅខាងកំពង់ស្ពឺ ។

សុវណ្ណ៖ ក្រោយមកបានបងហឹង មកដាប់រហូតទៅ?

ហេន៖ ចា៎!

សុវណ្ណ៖ ហើយការងារនៅខាងរោងចក្រពេលហ្នឹងមីងគេឲ្យធ្វើអីខ្លះ?

ហេន៖ ឲ្យនៅតំបាញ ។

សុវណ្ណ៖ ដកពីទ័ពហើយគេឲ្យមកធ្វើតំបាញវិញ?

ហេន៖ តំបាញ ។

សុវណ្ណ៖ តំបាញការងារប្រចាំថ្ងៃមីងធ្វើអីគេ?

ហេន៖ ការងារប្រចាំថ្ងៃត្បាញរាល់តែថ្ងៃ ។

សុវណ្ណ៖ តែយើងត្បាញក្រណាត់ ឬត្បាញអីគេ?

ហេន៖ ត្បាញក្រណាត់ ត្បាញមុង កន្លែងហ្នឹងវាមានត្បាញក្រណាត់ ក្រមា មុង បង់អនាម័យ សំឡីអនាម័យ គេហៅខស្សរាហកម្មបរិក្ខាពេទ្យ មានច្រើនផ្នែកកន្លែងហ្នឹង ។

សុវណ្ណ៖ តែមីងភាគច្រើនតំបាញទេ?

ហេន៖ ចា៎! តំបាញ ។

សុវណ្ណៈ ការងាររយើងរធ្វើពីរម៉ោងប៉ុន្មាន ដល់រម៉ោងប៉ុន្មាន? ព្រឹករយើងចូលរធ្វើការរម៉ោងប៉ុន្មាន?

ហេនៈ ព្រឹកចាប់រផ្ដើមពីរម៉ោង៦-១១ ។

សុវណ្ណៈ ដល់រពលរយើងសំរាក ថ្ងៃរឡើងចូលរម៉ោងប៉ុន្មាន?

ហេនៈ ចូលពីរម៉ោង៣-១០យប់ បានបន្តរទៀត ។

សុវណ្ណៈ ចង់និយាយថារម៉ោង៦រយើងចូល រម៉ោង១១រយើងរចញ?

ហេនៈ ចាំ!

សុវណ្ណៈ រហើយរក្រាយមករយើងចូលថ្ងៃរម៉ោងប៉ុន្មានរទៀត?

ហេនៈ ចូលរម៉ោង៣ ។

សុវណ្ណៈ ចូលរម៉ោង៣ រចញរម៉ោងប៉ុន្មានមីង?

ហេនៈ រចញរម៉ោង១០យប់ ។

សុវណ្ណៈ រធ្វើយូររម្ល៉េះ?

ហេនៈ ២៤រម៉ោង ។

សុវណ្ណៈ រហើយមីងរធ្វើមួយថ្ងៃប៉ុន្មានរពល?

ហេនៈ ២ដង ២រពល ។

សុវណ្ណៈ រហើយការហូបចុករពលហ្នឹងខ្វះខាត ឬអត់រទ?

ហេនៈ អត់ខ្វះខាតរទ ។

សុវណ្ណៈ រគឲ្យរយើងហូបបាយ ឬហូបបបរ?

ហេនៈ ចូលដំបូងហូបនំប៉័ង ។

សុវណ្ណៈ ព្រឹក?

ហេនៈ ទាំងព្រឹក ទាំងថ្ងៃ ល្ងាច ។

សុវណ្ណៈ នំប៉័ងរយើងហូបជាមួយអីរគ?

ហេនៈ ហូបជាមួយសម្លររយើងធម្មតា ។

សុវណ្ណៈ អាំហ! នំប៉័ងជ្រលក់ជាមួយសម្លរ?

ហេនៈ ហ្នឹងរហើយហូបជាមួយសម្លរ ។

សុវណ្ណៈ រក្រាយមកបានរគឲ្យរយើងហូបអីរគ?

ហេនៈ ហូបជាមួយបាយ រក្រាយមកបាយលាយជាមួយរពាតក្រហមរហូត ។

សុវណ្ណៈ របស់ដែលរយើងរធ្វើបានរពងចក្រតម្បាញភាគរច្រើនយករទាខាងណាវិញ?

ហេនៈ អត់ដឹង អន្តការ ។

សុវណ្ណៈ តែមិនឃើញគេមកដឹកទាំងឡានៗទៅទេ?

ហេនៈ ចា៎! ឃើញគេដឹកយកទៅ ។

សុវណ្ណៈ តែដឹកយកទៅ ខាងណាអ្នកដឹកយកទៅ?

ហេនៈ ខាងកន្លែងមជ្ឈិម ។

សុវណ្ណៈ គេដឹកយកទៅណា? ចែកប្រជាជនទុកប្រើ ឬដឹកទៅណាវិញ?

ហេនៈ អត់ដឹង លឺថាប្រជុំមួងៗដឹកយកទៅចែកប្រជាជនទៅបរទេស ទៅក្រៅ ។

សុវណ្ណៈ អីចឹងដឹកយកទៅបរទេសទេ? លក់ទៅបរទេស?

ហេនៈ ចា៎!

សុវណ្ណៈ ហើយពេលធ្វើការនៅក្នុងរោងចក្រហ្នឹងមានខាងជំនាញការចិន គេមកជួយប្រាប់ ជួយណែនាំមានទេ?

ហេនៈ មាន ។

សុវណ្ណៈ គេកាន់ខាងអីគេ ជំនាញការចិនហ្នឹង?

ហេនៈ ចិនខាងជាង រវៃ អន្ទោង ។

សុវណ្ណៈ រោងចក្រមឹងមានប្រហែលប៉ុន្មាននាក់ជំនាញការចិនហ្នឹង?

ហេនៈ ជំនាញការចិនហ្នឹងមានខាងជាង អាចមានច្រើននាក់ដែរ ១០នាក់ ។

សុវណ្ណៈ កម្មករធ្វើរោងចក្រមានប៉ុន្មាននាក់?

ហេនៈ ៧០០នាក់ក្នុងមួយរោងចក្រ ទាំងបុរស ស្ត្រី កុមារ ទាំងវ័យកណ្ដាល វ័យចាស់រួមគ្នាទាំងអស់ ។

សុវណ្ណៈ ពេលសំរាកយើងអត់ធ្វើការធ្វើអីវិញពេលសំរាក?

ហេនៈ ពេលសំរាកម៉ោងយើងអត់ចូលទៅត្បាញ ដល់យើងទៅពលកម្មខាងក្រៅ ទៅលើកទំនប់ ជីកប្រឡាយ ទៅផ្ទាក់ដីស្រែ ខែស្ទូងទៅដក ទៅស្ទូង ។

សុវណ្ណៈ ទៅដកខាងណាវិញ?

ហេនៈ ទៅខាងបឹងជើងឯក បឹងទំពន់ មកខាងរោងចក្រកែវ ។

សុវណ្ណៈ មានទៅដាំបន្លែដែរ?

ហេនៈ ដាំដូចគ្នា ។

សុវណ្ណៈ គេឲ្យយើងធ្វើការមួយអាទិត្យពេញទាំងមួយអាទិត្យ ឬមានពេលសំរាកខ្លះ?

ហេនៈ សំរាក ។

សុវណ្ណៈ ថ្ងៃសៅរ៍ អាទិត្យដែលមានអត់ទេ?

ហេនៈ អត់មានសំរាកទេ ថ្ងៃសៅរ៍ អាទិត្យទៅពលកម្មក្រៅ ។

សុវណ្ណៈ អីចឹងបានន័យថាយើងធ្វើការពីថ្ងៃច័ន្ទ-សុក្រ ធ្វើនៅរោងចក្រ សៅរ៍ អាទិត្យគេឲ្យយើងសំរាកបានពីរថ្ងៃដែរ? អត់ធ្វើរោងចក្រ?

ហេនៈ គេសំរាកចេះ តែថ្ងៃ១០ ថ្ងៃ២០ទេ មានថ្ងៃ១០ ថ្ងៃ២០ទេសំរាក ។

សុវណ្ណៈ ១០ថ្ងៃគេសំរាកម្តង?

ហេនៈ ចាំ! ១០ថ្ងៃគេសំរាកម្តង ម្តងហ្នឹងអត់មែនសំរាកនៅផ្ទះយើងធម្មតាទេ ទៅធ្វើការពលកម្មនៅក្រៅ ។

សុវណ្ណៈ ទៅដាំបន្លែ ទៅស្ទូង នៅតាមដើងឯក ទំនប់បឹងទំពន់ រោងចក្រកែវមីង?

ហេនៈ ចាំ! គ្រប់កន្លែង ។

សុវណ្ណៈ នៅពេលហ្នឹងភ្នំពេញយ៉ាងម៉េចដែរមីង កាលមីងទៅភ្នំពេញដំបូងៗ?

ហេនៈ ទៅដំបូងស្ងាត់ដែរ ។

សុវណ្ណៈ មីងដឹងថាហេតុអីបានភ្នំពេញស្ងាត់អីចឹង?

ហេនៈ ស្ងាត់ ។

សុវណ្ណៈ មីងគិតយ៉ាងម៉េចភ្នំពេញស្ងាត់អីចឹង?

ហេនៈ ស្ងាត់បើកាលរំដោះគេថាបណ្តេញប្រជាជនឲ្យចេញអស់ហើយ ។

សុវណ្ណៈ អារម្មណ៍ដែលយើងមកភ្នំពេញដំបូង យើងគិតថាភ្នំពេញយ៉ាងម៉េច? ពេលយើងជិះទូកមកដំបូង ជិះកាណូត?

ហេនៈ នឹកឃើញថា ដូចថាដំបូងអីចឹងឃើញប្រជាជនវែក លី សែង វែកឥវ៉ាន់ចេញពីទីក្រុងភ្នំពេញ នឹកឃើញថាទីក្រុងគ្មានមនុស្សរស់នៅ ។

សុវណ្ណៈ ខ្ញុំចង់និយាយថាអារម្មណ៍មីងថា គេប្រាប់ថាមកធ្វើការភ្នំពេញ ភ្នំពេញបែបសប្បាយ មីងគិតក្នុងចិត្ត ហើយមីងធ្លាប់មកភ្នំពេញពីមុនមកអត់?

ហេនៈ ធ្លាប់មកពីមុនវាសប្បាយ ដល់ពេលនឹកឃើញថា ក្នុងចិត្តក្នុងអារម្មណ៍អត់នឹកឃើញថាសប្បាយទេ នឹកឃើញថាស្ងាត់ព្រោះវាគ្មានមនុស្ស មានតែអ្នកទៅធ្វើការ ស្ងាត់ណាស់ភ្នំពេញ ។

សុវណ្ណៈ ចុះយប់ឡើង បរិយាកាសយ៉ាងម៉េចដែរ? ស្ងាត់ស្ងៀមអីចឹង?

ហេនៈ យប់ឡើងគឺស្ងាត់មានតែពួកទ័ពគេដើរធ្វើការ ល្បាតតាមផ្លូវ តាមមាត់ទន្លេ ឃើញតែប៉ុណ្ណឹងឯង ។

សុវណ្ណៈ យើងលឺសូរសំលេងអីយប់ឡើងអីអត់ទេ?

ហេន៖ អត់ ។

សុវណ្ណ៖ អត់លឺសំលេងអីយប់ឡើងទេមីង?

ហេន៖ ចាំ!

សុវណ្ណ៖ ចង់ថាលឺសូរតែសំលេងឡានគេបើកទៅ ឡានគេបើកមកមួយៗ យូរៗលឺសូរម្តង?

ហេន៖ យូរៗលឺសូរមួយ គេបើកទៅមានការដូចថាដឹកក្រណាត់ ដឹកគ្រឿងចក្រ បន្ទាស់មកប្តូរតាមរោងចក្រ ។

សុវណ្ណ៖ មីងគិតថាបរិយាកាសប្ញក៏ទិដ្ឋភាពនៅភ្នំពេញពេលហ្នឹងយ៉ាងម៉េចដែរពេលហ្នឹង? សំរាប់មីងផ្ទាល់?

ហេន៖ អារម្មណ៍ខ្ញុំផ្ទាល់មានចិត្តថាធុញថប់ដែរ ត្រង់ថាគ្មានមនុស្ស បើបានទៅធ្វើការខាងក្រៅៗទៅកន្លែងកសាងជាសំណង់ ធ្វើជាស្អីមួយហ្នឹងមានគ្នាច្រើន នឹកឃើញថាសប្បាយបន្តិចទៅ

សុវណ្ណ៖ មីងនៅម្តុំណាពេលធ្វើការរោងចក្រក្បាលថ្នល់? ពេលធ្វើការចប់ទៅស្នាក់នៅឯណា?

ហេន៖ ស្នាក់នៅកន្លែងរោងចក្រ ។

សុវណ្ណ៖ ជិតរោងចក្រដែរទេ អត់ឆ្ងាយទេ?

ហេន៖ រោងចក្របេះផ្ទះនៅតាមថ្នល់ ខ្លះនៅអមសងខាងផ្ទះ ។

សុវណ្ណ៖ ទៅធ្វើការជិះអីទៅ?

ហេន៖ អត់ជិះអីទេ ដើរទៅ ។

សុវណ្ណ៖ ដើរទាំងហ្វូងៗទាំងអស់គ្នាទៅ?

ហេន៖ ទាំងហ្វូងគ្នាមួយក្រុមៗ ។

សុវណ្ណ៖ ពេលយើងដើរទៅធ្វើការយើងមាននិយាយអីជាមួយតាមផ្លូវខ្លះទេ?

ហេន៖ មានអារម្មណ៍ក្នុងមួយថ្ងៃៗ ចុះនៅធ្វើការជិតរោងបាយ ខាងផ្ទះបាយគេធ្វើម្ហូបអីជះចូលទៅដល់ហ្នឹងហេវបាយ នឹកឃើញថាគេធ្វើអីបានឆ្ងាញ់ ហូបបានក្រែលទៅ បើថាអត់ឆ្ងាញ់ហូបបានមួយចាន ។

សុវណ្ណ៖ ពេលយើងធ្វើការមានជួបផលលំបាកអីខ្លះពេលហ្នឹង?

ហេន៖ មាន ។

សុវណ្ណ៖ ផលលំបាកជួបរបៀបម៉េចទៅ?

ហេន៖ ដូចថា ផលលំបាកពេលដែលកីខូចយើងពិភាក្សាជាមួយបុរស ដូចថាយើងជាស្រី ជាងប្រុសហើយយើងហៅគេទៅធ្វើកី គេធ្វើបណ្តើរយើងសួរនាំគេនិយាយច្រើនប្រធានក្រុម

ប្រធានពួកសំលឹងមើល យប់ឡើងទៅប្រជុំកសាង អត់ឲ្យនិយាយ សូម្បីតែបងប្អូនជួបគ្នា និយាយរកគ្នាក៏បានដែលកាលនោះ ។

សុវណ្ណៈ គេប្រជុំយ៉ាងម៉េចដែលមីង ប៉ុន្មានថ្ងៃគេប្រជុំម្តង ឬប៉ុន្មានខែគេប្រជុំម្តង? ប្រជុំជីវភាពយប់ឡើង?

ហេនៈ ប្រជុំពួកប្រជុំរាល់យប់ ។

សុវណ្ណៈ ប្រជុំពួកហ្នឹងប្រជុំជីវភាពមែន?

ហេនៈ ហ្នឹងហើយប្រជុំជីវភាព ។

សុវណ្ណៈ ប្រជុំរាល់យប់?

ហេនៈ ហ្នឹងហើយ ។

សុវណ្ណៈ ប្រជុំពីម៉ោងប៉ុន្មានដល់ម៉ោងប៉ុន្មាន?

ហេនៈ ប្រជុំពនាក់អីចឹង មួយពួកៗមួយភ្លែតៗទេហើយ ។

សុវណ្ណៈ ចុះយើងប្រជុំជុំគ្នាធំ?

ហេនៈ បើប្រជុំជាក្រុមពថ្ងៃ អីចឹងប្រជុំរួមជាក្រុមម្តង ។ មួយក្រុមហ្នឹងប៉ុន្មានពួក មាន៤ពួករួមគ្នាប្រជុំ ៣ថ្ងៃប្រជុំពួក ប្រជុំក្រុមម្តង ។

សុវណ្ណៈ ចុះប្រជុំក្រុមទាំងមូល?

ហេនៈ ប្រជុំធំមួយអង្គភាពមាន១០ថ្ងៃប្រជុំម្តង ។

សុវណ្ណៈ ហ្នឹងប្រជុំជុំគ្នាទាំងអស់តែម្តង?

ហេនៈ ចាំ!

សុវណ្ណៈ ហើយអ្នកណាច្រើនដឹកនាំការប្រជុំហ្នឹង? ប្រជុំធំ?

ហេនៈ បើមិនប្រធានធំ មានតែប្រធានធំ និងអនុប្រធាន ។

សុវណ្ណៈ គេប្រជុំច្រើននិយាយពីរឿងអីគេខ្លះ?

ហេនៈ និយាយជំរុញឲ្យយើងខំប្រឹងប្រែងធ្វើការងារហ្នឹង ។

សុវណ្ណៈ ហើយយើងដែលលើកផលវិបាកការងារយើងប្រាប់គេដែលអត់ទេ?

ហេនៈ អត់ហ៊ាន ។

សុវណ្ណៈ នៅក្នុងអង្គប្រជុំមានអ្នកផ្សេងលើកអីអត់ទេ?

ហេនៈ បើគេអ្នកហ៊ានគេហ៊ានលើក មានតែខាងផ្នែកៗគេ ខាងផ្នែកតំបាញរាយការណ៍ទៅ ផ្នែកខាងរវៃ ខាងរហាត់គេរាយការណ៍ឲ្យម្តងៗ ។

សុវណ្ណៈ ពេលរាយការណ៍លើកហើយគេមានដំណោះស្រាយឲ្យយើងខ្លះទេ?

ហេនៈ ចាំ! គេដោះស្រាយឲ្យយើង ។

សុវណ្ណៈ អ្នកធ្វើការជាមួយគ្នាមីងមានកត់សំគាល់ឃើញថាមានអ្នកបាត់ខ្លួន?

ហេនៈ មាន ។

សុវណ្ណៈ បាត់មានដឹងថាគេទៅណាទេ?

ហេនៈ គេប្រាប់យើងមិនត្រង់ តែក្នុងអារម្មណ៍យើងគិតថាតែបាត់ខ្លួនមានតែផ្លូវមួយទេ សព្វថ្ងៃខំប្រឹងធ្វើមិនឲ្យមានល្អក់កករជាមួយគេ កុំឲ្យគេបញ្ជូនឲ្យទៅរៀនសូត្រនៅកន្លែងនេះ ។

សុវណ្ណៈ ដឹងថាគេយកទៅណាអត់ទេ?

ហេនៈ ដឹងតែអត់ហ៊ាននិយាយ ។

សុវណ្ណៈ ដឹងថាគេយកទៅណា?

ហេនៈ ដឹងថាគេយកទៅសម្លាប់ចោល ។

សុវណ្ណៈ សម្លាប់ចោលនៅណា?

ហេនៈ នៅព្រៃស ។

សុវណ្ណៈ ម៉េចនៅព្រៃស មិនមែនមន្ទីរស-២១ទេ?

ហេនៈ ហ្នឹងហើយស-២១ ។

សុវណ្ណៈ នៅទួលស្លែងហ្នឹង?

ហេនៈ ទួលស្លែង ។

សុវណ្ណៈ មីងកាលហ្នឹងស្គាល់ទួលស្លែងទេ?

ហេនៈ លឺតែមិនបានទៅឃើញ ។

សុវណ្ណៈ កាលជំនាន់មីងធ្វើការនៅរោងចក្រ ដឹងថាមានទេ?

ហេនៈ ដឹងថាមាន ។

សុវណ្ណៈ មីងធ្វើម៉េចដឹងថាមាន?

ហេនៈ លឺខាងលើៗគេនិយាយ ។

សុវណ្ណៈ គេនិយាយថាម៉េច?

ហេនៈ គេនិយាយថាមានដាក់គុក ណែនាំ ខ្លះថាយកទៅអប់រំនៅកន្លែងអគ្គការ ។

សុវណ្ណៈ មីងអាចកត់សំគាល់ឃើញថាអ្នកដែលបានបាត់ខ្លួនភាគច្រើន អ្នកហ្នឹងមានធ្វើខុសអីខ្លះអត់ទេ?

ហេនៈ តែក្នុងក្រុម សមាជិក ពិនិត្យមើលទៅមិនឃើញខុសអីទេ តែកិច្ចការផ្ទៃក្នុងគេម៉េចមិនដឹងទេកាលហ្នឹង សង្កេតមើលមិនឃើញខុសអី ។

សុវណ្ណៈ សំរាប់មីងផ្ទាល់ដល់ពេលមីងឃើញអីចឹងហើយ មីងយល់ឃើញថារបបហ្នឹងយ៉ាងម៉េចដែរ? ដែលមីងខំតស៊ូ ឡើងទៅវៃ ទៅច្បាំងជាមួយគេ ដល់ក្រោយមកគេឲ្យទៅធ្វើការ ឃើញគេចាប់មនុស្ស ទៅអប់រំ ទៅសម្លាប់ ទៅដាក់គុក ៗ ដល់ក្រោយមកមីងយល់ឃើញថារបបហ្នឹងយ៉ាងម៉េច រស់នៅគ្មានសេរីភាព គ្រាន់តែនិយាយស្តីជាមួយប្រុសតិចតួចគេថាយើងខុសសីលធម៌ នៅក្នុងអំឡុងហ្នឹងមីងយល់ឃើញថារបបហ្នឹងយ៉ាងម៉េច នៅពេលហ្នឹង?

ហេនៈ កាលហ្នឹងយល់ថារបបផ្តាច់ការ របបនេះរបបផ្តាច់ការ អត់មានលើកលែងបានឃើញយើងខុសអត់មានជួយអប់រំ ជួយកសាង មានតែយកទៅ បញ្ជូនទៅអង្គការ ដឹងតែអង្គការ តែក្នុងអារម្មណ៍ ក្នុងខ្លួន ក្នុងចិត្តគេយកទៅមានតែផ្លូវម្យ៉ាង បេះតែគិតអីចឹង ព្រោះវាបាត់ដូចថា៤-៥ខែ បាត់មេៗអស់១-២នាក់ សូម្បីតែប្រធានពួកក៏ខ្លាចញញើត ខ្លាចធ្វើខុស

សុវណ្ណៈ ហើយមីងនៅធ្វើការនៅនោះរហូតគេវៃបែកភ្នំពេញតែម្តង ខាងវៀតណាមគេវៃបែកភ្នំពេញ៧៩ ឬយើងមានផ្លាស់ទៅធ្វើការនៅណាផ្សេងទៀត? ក្រោយមកយើងនៅធ្វើរោងចក្រដដែល ឬក៏យើងផ្លាស់ទៅធ្វើកន្លែងផ្សេង?

ហេនៈ នៅរោងចក្រដដែល ៗ

សុវណ្ណៈ ហើយអត់មានផ្លាស់ទៅធ្វើណាណីទេ?

ហេនៈ អត់ទេ ៗ

សុវណ្ណៈ យើងមានបានដើរទៅណាខ្លះទេពេលហ្នឹង? នៅភ្នំពេញដើរទៅលេងខាងនេះ ទៅលេងខាងនោះ?

ហេនៈ អត់បានដើរទេ បើទៅមានតែទៅធ្វើការ ៗ

សុវណ្ណៈ ហើយមានទៅចូលរួមមើលល្ខោន មើលកុនជាមួយគេទេ?

ហេនៈ មើលកុន ១០ថ្ងៃគេយកកុនទៅបញ្ចាំងឲ្យយើងមើលម្តង នៅរោងកុនដើមគរ រោងកុនបូកគោ យកយើងទៅមើលម្តងៗ ៗ

សុវណ្ណៈ ១០ថ្ងៃម្តង?

ហេនៈ ចា៎! ១០ថ្ងៃ ៗ

សុវណ្ណៈ កុនច្រើននិយាយពីកុនអីគេ?

ហេនៈ យកតែកុនចិន សិល្បៈយកពួកសិល្បៈខាងមជ្ឈិមលេងគេយកយើងទៅមើល ៗ

សុវណ្ណៈ តែកុនគេច្រើនយកកុនបដិវត្តន៍ កុនរឿងលក្ខណៈបែបម៉េច កុនរបស់គេ?

ហេនៈ យកតែកុនរបស់ចិនមកបញ្ចាំង ៗ

សុវណ្ណៈ	កុនចិនឲ្យយើងមើលហ្នឹងកុនភាគច្រើនប្រភេទរឿងអីគេ? តស៊ូ?
ហេនៈ	រឿងអ្នកតស៊ូ គេអ្នកក្រីក្រ អ្នកតស៊ូប្រយុទ្ធ អ្នកដែលកាន់អំណាចធំៗធ្វើបាបអ្នកតូចទាប
សុវណ្ណៈ	ហើយសិល្បៈគេប៉ុន្មានថ្ងៃ?
ហេនៈ	សិល្បៈទាល់តែមានកម្មវិធីធំ ដូចថាធ្វើមេទ្ធិញ ឬក៏បុណ្យរំដោះ១៧មេសា គេលេង។
សុវណ្ណៈ	ពេលទៅមើលកុនយើងទៅជិះអីទៅ? គេមានឡានធំរបស់គេ?
ហេនៈ	ឡានទៅ។
សុវណ្ណៈ	ទៅទាំងពេងចក្រទាំងមូលតែម្តងឬក៏ម៉េច?
ហេនៈ	ចាំ! គេដឹក អ្នកណាទៅមើលក៏ទៅៗ អ្នកណាមិនទៅមើលក៏ហីទៅ នៅផ្ទះទៅ អ្នកណាគេចង់ទៅមើលចង់ទៅ។
សុវណ្ណៈ	គេច្រើនលេងម៉ោងប៉ុន្មាន?
ហេនៈ	លេងម៉ោង៧-៨ ទៅ១០គេឈប់ ម៉ោង១១គេឈប់ គេដឹកយើងមកផ្ទះវិញ។
សុវណ្ណៈ	ហើយមីងមានចូលរួមខួបបក្សនៅស្ពាតខ្លះទេពេលហ្នឹង?
ហេនៈ	មាន។
សុវណ្ណៈ	ទៅចូលរួមគេហ្នឹងដែរ?
ហេនៈ	ចាំ! នៅស្ពាត។
សុវណ្ណៈ	ខួបបក្សរបស់គេ?
ហេនៈ	ចាំ!
សុវណ្ណៈ	បុណ្យបក្ស? ពេលហ្នឹងគេមានជប់លាង?
ហេនៈ	ចាំ! គេជប់លាង។
សុវណ្ណៈ	គេហូបចុកម៉េចដែរមីង? បរិបូរណ៍ទេ?
ហេនៈ	ហូបបរិបូរណ៍ហើយ គេឲ្យនំប័ុងយើងហូប។
សុវណ្ណៈ	ហើយកម្មវិធីគេចាប់ផ្តើមពីម៉ោងប៉ុន្មាន ដល់ម៉ោងប៉ុន្មានមីងកាលហ្នឹងបុណ្យបក្សគេ?
ហេនៈ	ចាប់ពីម៉ោង៨ ម៉ោង៧ អីចឹងទៅ ទៅដល់ម៉ោង១១ រហូតដល់ម៉ោង១ គេសំរាកហូបបាយមួយភ្លែតហ្នឹង គេចាប់ផ្តើមទៅទៀត កាលដែលធ្វើមេទ្ធិញធំ លោកអ៊ំខៀវ សំផន, វ៉ន វ៉េត ហ្នឹងធ្វើតាំងពីព្រឹក តាំងម៉ោង៧រហូតដល់ម៉ោង១១ ធ្វើនៅស្ពាតចាស់។
សុវណ្ណៈ	ភាគច្រើននិយាយរឿងអីគេ ពេលប្រជុំបក្សធំៗម្តងៗ បុណ្យបក្ស?
ហេនៈ	មិននិយាយអីទេ និយាយតែរឿងបក្ស រឿងតស៊ូ ប្រយុទ្ធ ទំកសាង ផលិតស្រូវមួយហិតាឲ្យបាន៣តោន។

សុវណ្ណៈ ចុះម្ហូបគេធ្វើដប់លាងគេធ្វើម្ហូបប៉ុន្មានមុខ?

ហេនៈ ម្ហូបធ្វើសម្លរការី ស្ងោរ ឆា ម្ជូរគ្រឿង ។

សុវណ្ណៈ ហើយមីងរត់៧៩រត់ពេលណាទៅ?

ហេនៈ រត់ ។

សុវណ្ណៈ ពេលវៀតណាមវ៉ៃចូល?

ហេនៈ ពេលវៀតណាមវ៉ៃចូលហ្នឹងនាំគ្នារត់ចេញពីភ្នំពេញមកតាមថ្នល់ជាតិលេខ៤ ។

សុវណ្ណៈ តែរត់ពេលណា? រត់ថ្ងៃណា?

ហេនៈ ថ្ងៃណាទេ រត់ចេញថ្ងៃណាទេភ្លេចបាត់ហើយ ។

សុវណ្ណៈ ថ្ងៃ៦មករាហ្នឹង? ដើមឆ្នាំ៧៩?

ហេនៈ ចាំ!

សុវណ្ណៈ កាលហ្នឹងរត់ៗទៅខាងណាវិញ?

ហេនៈ រត់ទៅខាងផ្លូវថ្នល់ជាតិលេខ៤ ទៅខាងភ្នំត្នោតពង ។

សុវណ្ណៈ រត់ទៅខាងកំពង់សោមវិញ ថ្នល់ជាតិលេខ៤ហ្នឹង?

ហេនៈ តាមថ្នល់ជាតិលេខ៤ ។

សុវណ្ណៈ កាលហ្នឹងយើងរត់ពេលយប់ ឬរត់ពេលថ្ងៃ?

ហេនៈ ទៅពេលយប់ ។

សុវណ្ណៈ ម៉ោងប្រហែលប៉ុន្មានយើងរត់?

ហេនៈ ខ្ញុំចេញម៉ោង៦-៧ហើយ ចេញទៅយប់ដេកនៅភ្នំត្នោតពង ។

សុវណ្ណៈ នៅខេត្តណា? កំពង់ស្ពឺ ឬក៏?

ហេនៈ កំពង់ស្ពឺ ។

សុវណ្ណៈ យើងរត់យើងជិះអី ឬក៏យើងដើរ?

ហេនៈ ដើរទៅរហូត ។

សុវណ្ណៈ យើងរៀបចំឥវ៉ាន់ទាន់ទេកាលហ្នឹង?

ហេនៈ ខ្លះក៏ទាន់ ខ្លះក៏អត់ទាន់ ។

សុវណ្ណៈ តែយើងដឹងសភាពការណ៍មុន?

ហេនៈ ដឹងមុន ។

សុវណ្ណៈ ដឹងមុនរបៀបម៉េច?

ហេនៈ ដឹងមុនអ្នកលើៗគេប្រាប់ថាសភាពការណ៍មិនស្រួល ព្រោះយួនគេមកវ៉ៃរំដោះយកភ្នំពេញ ដល់អីចឹងនាំគ្នារត់ភៀសខ្លួនចេញ គ្រប់កន្លែងទៅទាំងអស់មនុស្សឡើងរាប់ម៉ឺន រាប់ពាន់នាក់

សុវណ្ណៈ តែខ្ញុំចង់និយាយថា ពេលយប់ឡើងគេបាញ់គ្នាលឺសូរគ្រឹងគ្រាំងដែល?

ហេនៈ អត់ទាន់មានបាញ់ទេ ទាល់តែខ្ញុំរត់ទៅដេកនោះមួយយប់ ។

សុវណ្ណៈ ខ្ញុំចង់ថាដំបូងដែលមុនរត់?

ហេនៈ អត់ទាន់បាញ់ទេ គ្រាន់តែគេឲ្យយើងភៀសខ្លួនចេញមក អត់ទាន់មានបាញ់ទេ ។

សុវណ្ណៈ អីចឹងរត់ខ្ទង់៧-៨ទេ?

ហេនៈ ចា៎!

សុវណ្ណៈ ហើយរត់ទៅខាងផ្លូវជាតិលេខ៤?

ហេនៈ ចា៎! ទៅផ្លូវជាតិលេខ៤ ។

សុវណ្ណៈ កាលហ្នឹងរត់ជាមួយក្តីគ្នាជាមួយយើងហ្នឹង?

ហេនៈ ចា៎!

សុវណ្ណៈ កាលហ្នឹងម៉េចរត់ទៅខាងហ្នឹងអីចឹង?

ហេនៈ មិនដឹងម៉េចគេឲ្យទៅខាងហ្នឹង ។

សុវណ្ណៈ មានគេអ្នកដឹកនាំរត់ទៅ?

ហេនៈ អត់ដឹង អត់ដឹងពីណា តែឃើញតែទៅទាំងអស់គ្នាហ្នឹង អាចមានបែកផ្លូវទៅខាងនេះខ្លះ ទៅខាងផ្លូវជាតិលេខ៥ ទៅខាងអូរប្ញស្សី ។

សុវណ្ណៈ វៀតណាមមានតាមទាន់ទេ? តាមបាញ់ពីក្រោមទាន់ទេ?

ហេនៈ ខ្លះក៏ទាន់ទៅ ខ្លះអត់ទេ ។

សុវណ្ណៈ ហើយមីងរត់រហូតទៅដល់ណា?

ហេនៈ រត់ទៅដល់បាត់ដំបង ។

សុវណ្ណៈ ចូលទៅដល់ស្រុកណា?

ហេនៈ នៅខាងបាត់ដំបង ទៅនៅខាងស្តៅ ចូលពីស្តៅមកលាច ដើរកាត់មិនដឹងភូមិណា ស្រុកណាទេចេះតែដើរកាត់រហូត ។

សុវណ្ណៈ យើងហូបចុករបៀបម៉េចទៅតាមផ្លូវ?

ហេនៈ តាមផ្លូវបើអស់អង្ករ ទៅដល់កន្លែងភូមិមួយរកស្រូវ រកអង្ករគេបុក យកដាក់រទេះហូបទៀតទៅ បានស្រូវ អង្ករប្រជាជន ភូមិខ្លះក៏រត់អស់រលីងៗដូចតែគ្នា ។

សុវណ្ណៈ ក្រោយមកទៅដល់ណាទៀត?

ហេនៈ ក្រោយមកនៅម៉ាឡៃ ។

សុវណ្ណៈ អ៊ីចឹងវគ់ប៉ុន្មានថ្ងៃ ប៉ុន្មានសប្ដាហ៍បានទៅដល់ម៉ាឡៃ?

ហេនៈ រាប់ខែ តាំងពីខែវគ់ចេញហ្នឹងមក ខែ៤មកចូលឆ្នាំនៅ ។

សុវណ្ណៈ កូនដីរ?

ហេនៈ មិនមែនទេ នៅភូមិស្អី ។

សុវណ្ណៈ តែក្នុងខេត្តណា?

ហេនៈ ខេត្តកំពង់ស្ពឺ ។

សុវណ្ណៈ បើជិតទៅដល់ម៉ាឡៃ នៅខាងបាត់ដំបង ។

ហេនៈ អត់ទេ អត់ទាន់ទៅដល់ទេ វគ់ចូលទៅខាងស្អីទេ ។

សុវណ្ណៈ ទៅទឹកពុះ?

ហេនៈ ទៅតាមទឹកពុះចូលទៅដល់រលាក់កងជើង ។

សុវណ្ណៈ ឱរ៉ាល់?

ហេនៈ ចា៎! ឱរ៉ាល់ទៅរលាក់កងជើង ចេញទៅខាង ។

សុវណ្ណៈ យើងវគ់តាមថ្នល់ជាតិ ឬយើងវគ់តាមព្រៃ?

ហេនៈ តាមផ្លូវលំ ផ្លូវរទេះ ។

សុវណ្ណៈ អត់ដើរតាមថ្នល់ជាតិទេ?

ហេនៈ អត់ទេ ។

សុវណ្ណៈ មូលហេតុអី?

ហេនៈ ព្រោះគេនាំដើរផ្លូវកាត់វាឆាប់ទៅដល់ភូមិនេះ គេនាំទៅកាត់ បេះតែកាត់ដើរទៅរហូត ។

សុវណ្ណៈ អ៊ីចឹងយូរដែរ២-៣ខែ បានទៅដល់ម៉ាឡៃ?

ហេនៈ ចា៎! ២-៣ខែបានទៅដល់បវិល ទៅនៅបវេល-ថ្មគោល ។

សុវណ្ណៈ ថ្មគោលហើយ?

ហេនៈ បវេលឡើងមួយខែ ជញ្ជូនស្រូវពីព្រៃមកដាក់ក្នុងភូមិ ក្នុងស្រុក បានជញ្ជូនអស់ព្រៃ អំបិលជញ្ជូនពីព្រៃមកអស់ មានអីយួនបុកមកកុចស្រូវហ្នឹងបានយួនស៊ីទៅ អាខ្លួនឯងទៅ បានតែបុកអង្ករមួយទៃ១យកទៅហូប ។

សុវណ្ណៈ វគ់ហ្នឹងវគ់តាមកងពលណា? មានទ័ពជាមួយទេ ឬសុទ្ធតែអ្នករោងចក្រទាំងអស់?

ហេនៈ សុទ្ធតែអ្នកប្រជាជន អ្នករោងចក្រទាំងអស់ ។

សុវណ្ណៈ ទៅនៅជំបូងនៅបវេល?

ហេនៈ ចាំ!

សុវណ្ណៈ បវេលហើយបានមកខាងថ្មគោល?

ហេនៈ ចាំ! ថ្មគោល ។

សុវណ្ណៈ ថ្មគោលហើយបានទៅនៅខាងម៉ាឡៃ?

ហេនៈ ចាំ!

សុវណ្ណៈ ចូលទៅនៅបវេលនៅជាមួយខាងទ័ព ឬនៅខាងអីដែរ?

ហេនៈ នៅតាមអង្គភាព ។

សុវណ្ណៈ អង្គភាពរបស់ទ័ព ឬក៏អង្គភាពរបស់អីគេ?

ហេនៈ យើងទៅនៅខាងនេះ ដូចថាស្រុក ។

សុវណ្ណៈ ចុះមីងពេលចូលទៅនៅ មិនមែនទៅនៅខាងទ័ពទេ?

ហេនៈ អត់ទេ ។

សុវណ្ណៈ យើងនៅជាមួយប្រជាជន?

ហេនៈ នៅជាមួយតែគ្នាកង១គ្នាឯង ។

សុវណ្ណៈ តែមានទ័ពជាមួយទេ?

ហេនៈ មានពួកទ័ពតំបន់ ទ័ពស្រុក ខ្មាត់ខ្ចាយមកជាមួយគ្នាហ្នឹង អ្នកគេមកមុនគេនៅសំរាក នៅការពារហ្នឹង ទ័ពតំបន់នៅការពារគេដឹកនាំយើងទៅយកស្រូវពីក្នុងព្រៃ ហើយគេដឹកនាំផ្លូវយើងឲ្យយើងទៅណា ផ្លូវណាទៅណា ទៅផ្លូវណា ទៅភូមិណា គេនាំទៅ ទាក់ទងគេ ។

សុវណ្ណៈ ទៅដល់ណាទៀត? ចុងក្រោយបានទៅដល់ម៉ាឡៃ?

ហេនៈ ទៅដល់ ។

សុវណ្ណៈ ចេញពីថ្មគោលមក?

ហេនៈ ចេញពីថ្មគោលទៅតាមស្រែសាម៉ន ទៅខាងអូរគ្រាង ស្គាល់អូរគ្រាងទេ?

សុវណ្ណៈ អូរគ្រាងអីមីង?

ហេនៈ ចាំ! ទៅនៅអូរគ្រាង ។

សុវណ្ណៈ ក្រោយមកយើងទៅដល់ណាទៀតមីង?

ហេនៈ ទៅដល់អូរគ្រាង ។

សុវណ្ណៈ អូរគ្រាងនៅខាងណា?

ហេនៈ អូរគ្រាងនៅខាងព្រំដែនថៃ បន្ទាយម្លែម ។

សុវណ្ណៈ និយាយម្លែមខ្ញុំស្គាល់ ។

ហេនៈ	នៅហ្នឹង ។

សុវណ្ណៈ	ខ្ញុំធ្លាប់ទៅដែរ ។ ទៅនៅខ្មែម ទៅនៅខាងណា? ទៅនៅជាមួយខាងណា?

ហេនៈ	នៅជាមួយប្រជាជនដដែល ។

សុវណ្ណៈ	ហើយយើងបានអីហូបចុកមីង?

ហេនៈ	ទៅនៅកាលហ្នឹងខាងក្រុមសេដ្ឋកិច្ចគេចែកអង្ករឲ្យយើងហូបធម្មតា ។

សុវណ្ណៈ	កាលហ្នឹងគេមានបើករបបឲ្យយើងដែរ?

ហេនៈ	ចាំ! បើករបប ។

សុវណ្ណៈ	ខាងណាគេបើកឲ្យ?

ហេនៈ	ពួកខាងអង្គការដូចថាគេជំនួយយើង ដូចថាយើងអ្នកជនភៀសខ្លួនអីចឹងទៅ អង្គការខាងណា ៗ គេមកជួយ គេផ្តល់អង្ករឲ្យយើង ។

សុវណ្ណៈ	កាលហ្នឹងចូលទៅខាងជំរុំហើយ?

ហេនៈ	ថាខាងជំរុំចុះ ។

សុវណ្ណៈ	ជំរុំអូរត្រាវ?

ហេនៈ	អត់ទាន់បានទៅនៅជំរុំអូរត្រាវទេកាលហ្នឹង ។

សុវណ្ណៈ	អូរត្រាង?

ហេនៈ	ហ្នឹងហើយ ។

សុវណ្ណៈ	លក្ខណៈដូចជំរុំដែរ?

ហេនៈ	ហ្នឹងហើយ លក្ខណៈដូចគ្នា ។

សុវណ្ណៈ	ក្នុងដីថៃ ឬដីខ្មែរ?

ហេនៈ	មុនដំបូងនៅដីខ្មែរយើង ដល់យួនវាវ៉ៃទៅយើងរត់ចូលទៅនៅដីថៃ ។

សុវណ្ណៈ	ដីថៃទៅនៅខាងណា? ឈ្មោះអីកន្លែងហ្នឹង?

ហេនៈ	នៅចេញ-ចូល ៗ ។ ទៅនៅបកចុះបកឡើង២-៣សារ ទៅអូរល្ហុង ចេញពីអូរល្ហុងទៅនៅត្រាង ចេញពីត្រាងបកចូល នៅជាមួយពីណា មើលកងឃាយអី ឃាយមៀនដឹកជញ្ជូនគេឲ្យដឹកជញ្ជូន ។

សុវណ្ណៈ	ក្រោយមកចូលទៅកងដឹកជញ្ជូន?

ហេនៈ	ចាំ! កងដឹកជញ្ជូន ។

សុវណ្ណៈ	ឆ្នាំណាកាលហ្នឹង?

ហេនៈ	យើងរត់ទៅដល់ត្រាងហ្នឹង ហៅទៅនៅដឹកជញ្ជូន ។

សុវណ្ណៈ ឆ្នាំណា ខួង៧៩ ឬខួង៨០?

ហេនៈ ក្នុង៧៩ហ្នឹងឯង ។

សុវណ្ណៈ កងជីកជញ្ជូនឡូកងពលណា?

ហេនៈ មិនដឹងជាកងពលណាទេ កាលហ្នឹងគ្រប់មុខ ។

សុវណ្ណៈ មិនទាន់បានបង្កើតជាកងពលចេញទេ?

ហេនៈ នៅទេ នៅប្រឡូកប្រឡំគ្នាកាលហ្នឹង ។

សុវណ្ណៈ ក្រោយមកគេបង្កើតចេញជាកងពលអីគេ?

ហេនៈ កងពលកាលនោះ ។

សុវណ្ណៈ ៨៣០, ៨១៥?

ប្ដីៈ កាលនោះកងពលមានច្រើន តែកងពលខាងខ្ញុំ៨០១ ។

សុវណ្ណៈ គាត់ទៅខាងខ្សែមហ្នឹង?

ប្ដីៈ បាទ!

សុវណ្ណៈ ចុះ៨៣០នោះ?

ហេនៈ ៨៣០គេនៅប្រចាំផ្សេង ។

សុវណ្ណៈ តែនៅម្ដុំខាងណាវិញ?

ប្ដីៈ អត់ដឹងខាងណាមិនសូវស្គាល់គេផង ។

សុវណ្ណៈ ចុះ៨១៥?

ប្ដីៈ អត់សូវស្គាល់ទេ ។

សុវណ្ណៈ ៨៥០?

ប្ដីៈ អត់ ស្គាល់ច្បាស់៨០១, ៩២០ ហើយ៨១២ ។

សុវណ្ណៈ ពូនៅខាងនេះបានស្គាល់ច្បាស់ ។ ខ្ញុំចង់និយាយហ្នឹងនៅខាងខ្សែម ខាងម៉ាឡៃ ។ អីចឹងពូអត់ទាន់ទៅម៉ាឡៃទេកាលហ្នឹង?

ប្ដីៈ ខ្ញុំទៅដែរ ។

ហេនៈ នៅទាំងអស់គ្នា ។

សុវណ្ណៈ ពូគ្រួសាររបស់មីង ពូឈ្មោះសុខ សាន ហ្នឹង?

ប្ដីៈ សុខ កំសាន ។

សុវណ្ណៈ អីចឹងមីងយើងតទៀត ក្រោយមកយើងទៅដល់ណា ពេលចេញពីខ្សែមមានទៅណាទៀតទេ?

ហេនៈ ចេញពីខ្មែរមកមកនៅនេះ១០០២ ។

សុវណ្ណៈ អីចឹងខ្មែរនៅក្នុងមាំខ្មែរទេ?

ហេនៈ ចាំ!

សុវណ្ណៈ មកនៅ១០០២កាលហ្នឹងពីណាគេយកមកនៅ?

ហេនៈ កាលហ្នឹងកងពល៨០១ ។

សុវណ្ណៈ កងពលរបស់ពួកទៅយកមកនៅ?

ហេនៈ មកទាំងអស់គ្នា ឡើងមកនៅនេះទាំងអស់គ្នា ។

សុវណ្ណៈ ឆ្នាំណាកាលហ្នឹង?

ហេនៈ ឆ្នាំ៨០ ។

សុវណ្ណៈ មូលហេតុអីទៅយកកំលាំងនៅនោះពូ?

ហេនៈ អន្តភាពនៅនេះ ។

សុវណ្ណៈ ព្រោះថាអន្តភាពនេះខុះ?

ប្ដីៈ អត់ទេ អន្តភាពឈរជើងនៅខាងមុំព ដល់អីចឹងវាយតាំងពី១០០២ហ្នឹង ដល់ពេលអីចឹងកំលាំង៧៩ឆ្ងាយដល់នោះ ។

សុវណ្ណៈ បានន័យថាកំលាំងនៅបែក?

ហេនៈ បែក ។

សុវណ្ណៈ អីចឹងបែកចាប់ផ្ដើមប្រមូលកំលាំងមកវិញ?

ហេនៈ ចាំ!

សុវណ្ណៈ ដល់ក្រោយមកគេឲ្យចូលកំលាំងកងដឹកជញ្ជូនរបស់៨០១?

ហេនៈ ហ្នឹងហើយ៨០១ ។

សុវណ្ណៈ តែមីងចូល៨០១ហើយតែអត់ដឹងខ្លួនចូល៨០១ទេ?

ហេនៈ អត់ ។

សុវណ្ណៈ ក្រោយមកបានប្រមូលកំលាំងមីងចូលមកវិញ មកនៅខាង១០០២នេះ?

ហេនៈ ១០០២ ។

សុវណ្ណៈ នៅខាងមុំពពូ?

ប្ដីៈ បាទ!

សុវណ្ណៈ ១០០២នៅខាងណាពូមុំព?

ប្ដីៈ ១០០២នៅខាងប្រកអានសេះ ។

សុវណ្ណៈ	កន្ទុយនាគ?
ប្ដីៈ	អត់ទេ ។
ហេនៈ	កន្ទុយនាគទន្លេល្ពៅមុំ៣ ។
សុវណ្ណៈ	មុំ៣ហ្នឹងយ៉ាងម៉េចពូ? វាព្រំដែន?
ប្ដីៈ	ព្រំដែនយួន ថៃ ខ្មែរ ។
សុវណ្ណៈ	ហើយវានៅជាប់គេហៅអីគេ? មុំ៣ហ្នឹង?
ប្ដីៈ	មុំ៣គេដាក់១០០១ ។
សុវណ្ណៈ	មិនមែន១០០២ទេ?
ហេនៈ	១០០២នៅខាងនេះ ។
ប្ដីៈ	១០០២នៅខាងពោយព្រេច ។
សុវណ្ណៈ	អីចឹងមីងកាលទៅ ទៅខាង១០០១?
ហេនៈ	ទៅ១០០២មុន នៅ១០០២ហើយបានដកពី១០០២ទៅនៅ១០០១ ទៅនៅមុំ៣ ។
សុវណ្ណៈ	១០០២នៅខាងមុំ៣?
ហេនៈ	អត់ទេ ១០០២នៅខាងច្រក១០០២ផ្សេងនៅខាងនេះ ។
សុវណ្ណៈ	ចុះ១០០១នៅខាងណា?
ហេនៈ	១០០១នៅមុំ៣ ។
សុវណ្ណៈ	ចុះកន្ទុយនាគ?
ហេនៈ	គេហៅកន្ទុយនាគហ្នឹង មុំ៣ហ្នឹង ។
សុវណ្ណៈ	កន្ទុយនាគហ្នឹងមុំ៣?
ហេនៈ	កន្ទុយនាគនៅខាងរតនគិរី ព្រំដែនយួន ។
សុវណ្ណៈ	ហ្នឹងកន្ទុយនាគ?
ហេនៈ	កន្ទុយនាគ ។
សុវណ្ណៈ	អីចឹងយើងមានមុំ៣ផ្សេង យើងមានកន្ទុយនាគផ្សេងអត់ដូចគ្នាទេ ។
ហេនៈ	អត់ដូចគ្នាទេ ។
សុវណ្ណៈ	កន្ទុយនាគនៅខាងរតនគិរីទេ?
ហេនៈ	រតនគិរី ។
សុវណ្ណៈ	ដល់ពេលមុំ៣យើងនៅខាង?
ហេនៈ	១០០១ ។

សុវណ្ណៈ	យល់ហើយអ៊ីចឹង ។ កន្ទុយនាគហ្នឹងមានលេខរៀងគេមួយពាន់ប៉ុន្មានៗទេ?
ហេនៈ	អត់ ។
ប្ដីៈ	មានតែយើងអត់ដឹង ។
សុវណ្ណៈ	អ៊ីចឹងដឹងថានៅមុំ៣ គឺ១០០១ អ៊ីចឹងមីងមុនដំបូងនៅ១០០២?
ហេនៈ	១០០២ ។
សុវណ្ណៈ	១០០២នៅខាងណា?
ហេនៈ	នៅព្រះវិហារ ។
សុវណ្ណៈ	ខាងព្រះវិហារ?
ហេនៈ	ចាំ! ប្រកហ្នឹង
សុវណ្ណៈ	នៅក្នុងស្រុកណាវិញរបស់ព្រះវិហារ?
ប្ដីៈ	ជាំក្សាន្ត ។
សុវណ្ណៈ	ហើយនៅក្នុងស្រុកណារបស់ឧត្តរមានជ័យ?
ប្ដីៈ	គេរៀបចំចូលឧត្តរមានជ័យ ។
ហេនៈ	ស្រុកអន្លង់វែង ត្រពាំងប្រាសាទនេះ ចាប់ផ្ដើមត្រឹមស្ទឹងខៀវមកកាត់ខាងនេះខេត្តឧត្តរមានជ័យ ខាងនោះខេត្តព្រះវិហារ ។
សុវណ្ណៈ	ខ្ញុំអត់សូវច្បាស់ហ្នឹងតិច ខ្ញុំសួរបញ្ជាក់ហ្នឹងតិច ព្រោះខ្ញុំច្រលំមុំ៣ កន្ទុយនាគជាមួយគ្នា ព្រោះវាកែងមកជាមួយគ្នាដដែល តែខុសគ្នា ។ អ៊ីចឹងមីងទៅដំបូង១០០២ទេ?
ហេនៈ	ចាំ!
សុវណ្ណៈ	១០០២របស់កងពល៨០១?
ហេនៈ	៨០១ ។
សុវណ្ណៈ	៨០១ប្រធានកងពលពីណាគេ?
ប្ដីៈ	កាលនោះបំបែកមកហើយ ចាំទទួល១០០២តាជាតិ ។
សុវណ្ណៈ	មិនមែនតា០៥ទេ?
ប្ដីៈ	មិនមែនទេ តា០៥ទទួល៨០១នៅខាងមុំ៣ ។
សុវណ្ណៈ	អ៊ីចឹង៨០១ក្រោយមកបែងចែកជា២?
ហេនៈ	ចាំ!
ប្ដីៈ	ចេញជា៣នោះ ។
សុវណ្ណៈ	ខ្ញុំចង់ថាពេលដែលយើងដួលរលំរបបខ្មែរក្រហមហើយ៨០១ចែកចេញជា៣?

ហេនៈ ៣ ។

សុវណ្ណៈ ទី១ នៅខាង១០០១ ។

ប្ដីៈ នៅខាង១០០១ខ្លះ នៅខាង១០០២ នៅ១០០៣ទៀត ។

ហេនៈ ខាង១០០៣ខ្លះ ។

សុវណ្ណៈ តែនៅខាង១០០២មីងទៅមាន៨០១ដែរ តែ៨០១អ្នកគ្រប់គ្រង១០០២ពីណាគេ?

ហេនៈ តាឈាន ។

ប្ដីៈ មិនមែនតាឈានទេ ។

សុវណ្ណៈ តាឈាន គាត់គ្រប់គ្រងខាងអីគេ?

ប្ដីៈ កងពល ។

ហេនៈ កងពល ។

សុវណ្ណៈ កងពលធំ?

ប្ដីៈ កងពលតូចទេគាត់ តែគាត់មកខាងភ្នំពេញ ។

សុវណ្ណៈ ហើយតាមួយទៀត?

ប្ដីៈ តាហឿន ។

ហេនៈ តាហឿន នៅទទួលខាង១០០៣នេះ នៅប្រេកនេះ ។

សុវណ្ណៈ ដល់ពេលមីងទៅហ្នឹង ទៅធ្វើអីនៅហ្នឹង១០០២?

ហេនៈ ទៅដឹកជញ្ជូនដែរ ។

សុវណ្ណៈ កងដឹកជញ្ជូនដែរ?

ហេនៈ ចាំ!

សុវណ្ណៈ ហើយប្រធានគ្រប់គ្រងមីងផ្ទាល់ពីណាគេ?

ហេនៈ គ្រប់គ្រងខ្ញុំកាលហ្នឹងដឹកជញ្ជូនហ្នឹងតាថន, យាយយូត ។

សុវណ្ណៈ យាយថន ប្រធាន ប្អូនុ?

ហេនៈ យាយថន ។

សុវណ្ណៈ ដល់ពេលទៅនោះនៅបានប៉ុន្មានខែ១០០២?

ហេនៈ នៅយូរដែរ ។

សុវណ្ណៈ ឆ្នាំណាបានទៅ១០០១?

ហេនៈ ជាប់មួយឆ្នាំជាង ។

សុវណ្ណៈ ក្រោយមកម៉េចទៅ១០០១វិញ?

ហេន៖ ឪទៅអន្លក់ភាព ខ្ញុំយកឪនៅ១០០២ ។

សុវណ្ណ៖ ក្រោយមកពូត្រឡប់ទៅអន្លក់ភាព១០០១វិញ?

ហេន៖ ទៅ១០០១ក៏ទៅទាំងអស់គ្នា ។

សុវណ្ណ៖ ទៅជាមួយគ្នាទៅ? មិនមែនខាងនោះវ៉ៃទេ?

ហេន៖ អត់ទេ ។

សុវណ្ណ៖ អត់ទាន់វ៉ៃទេកាលហ្នឹង?

ហេន៖ អត់ទាន់វ៉ៃ ។

សុវណ្ណ៖ រស់នៅ១០០២បានមួយឆ្នាំបានផ្លាស់ទៅ១០០១?

ហេន៖ ចា៎!

សុវណ្ណ៖ ទៅ១០០១នៅខាងកងពល៨០១ដដែលទេ?

ហេន៖ ៨០១ដដែល ។

សុវណ្ណ៖ ដល់ពេល១០០១ពីណាគ្រប់គ្រងពូ?

ប្តី៖ គ្រប់គ្រងកងពលធំតា០៥ ។

ហេន៖ តា០៥ ។

ប្តី៖ តា០៥ផង តា០៦, ៩០២តា០៦ ហើយភូមិភាគកណ្តាលតាពក ចំរុះគ្នា ។

សុវណ្ណ៖ នៅ១០០១មានប៉ុន្មានកងពល?

ប្តី៖ មាន៣ ។

សុវណ្ណ៖ ៣កងពល៨០១, ៩២០?

ហេន៖ កងតាពក ហៅកងអី ។

សុវណ្ណ៖ ៤១២?

ប្តី៖ ៤១២ហ្នឹងតាពក ។

ហេន៖ ៤១២តាពក ។

សុវណ្ណ៖ ហើយនៅហ្នឹងទៅណាទៀតក្រោយមក?

ហេន៖ គ្មានទៅណាទេ មានតែរត់មកនេះ ។

ប្តី៖ រត់មកបែកខ្ចាត់ខ្ចាយ រត់មកធ្លាក់មកនៅប្រាច់ ។

សុវណ្ណ៖ ដល់ពេលគេវ៉ៃ គេវ៉ៃឆ្នាំណាពូ?

ប្តី៖ អត់ចាំទេ ។

សុវណ្ណ៖ ខាងវៀតណាមគេវ៉ៃ?

ហេន: ហ្នឹងហើយ ។

សុវណ្ណ: វ៉ៃយើងរត់ទៅដល់ណាវិញ?

ប្ដី: រត់ធ្លាក់មក១០០៣ ។

ហេន: គៀសខ្លួនទៅប្រាច់ ។

សុវណ្ណ: ប្រាច់នៅលើភ្នំដងរែកដែលទេ?

ហេន: ដងរែក ។

សុវណ្ណ: ប្រាច់ហ្នឹងកន្លែងអីគេ?

ហេន: កន្លែងតាម៉ុក ។

សុវណ្ណ: ហ្នឹងគេហៅអីគេ? មានលេខ១០០១, ១០០៣?

ហេន: ចូល១០០៣ ។

សុវណ្ណ: អីចឹងរត់ទៅ១០០៣វិញ? រត់ទៅចូលជាមួយតាម៉ុក វិញ?

ហេន: តាម៉ុក ។

សុវណ្ណ: អីចឹងតាម៉ុក គ្រប់គ្រងនៅ១០០៣?

ហេន: គាត់នៅគ្រប់គ្រងទាំងអស់ ក្នុងកង៨០១ដដែល ។

សុវណ្ណ: គ្រាន់តែតាម៉ុក គ្រប់គ្រងធំ តែគាត់ប្រចាំការនៅខាង១០០៣?

ហេន: ចាំ!

សុវណ្ណ: ដល់ពេលទៅនៅហ្នឹងយ៉ាងម៉េចទៀតមីង?

ហេន: ចេញពីហ្នឹងមកនៅច្រកយើងអូរគ្រាវ ។

សុវណ្ណ: ចុះពីលើភ្នំមកនៅក្រោមនេះឆ្នាំណា? ចុះមកដំបូងបំផុត?

ហេន: ចុះដំបូងបំផុតខ្ញុំមកនៅ៩៣ ។

សុវណ្ណ: ៩០អី ព្រោះ៩០វ៉ៃបានអន្លង់វែង?

ប្ដី: ខ្ទង់៩០ ។

សុវណ្ណ: ៩០ចុះមកដំបូងនៅណា?

ប្ដី: នេះនៅគេហៅទំនប់ដាច់ ។

សុវណ្ណ: ចុះមកនៅទំនប់ដាច់ អត់នៅព្រះប្រឡាយសិន?

ហេន: អត់ទេ ។

សុវណ្ណ: ដល់ពេល៩០ខាងនោះគេវ៉ៃមកវិញ យើងរត់ទៅណាវិញ?

ប្ដី: ទៅនៅអូរស្មាយ ។

សុវណ្ណៈ	ពេលគេបែកមកវិញ? យើងទៅនៅអូរស្វាយ?

ហេនៈ	នៅអូរស្វាយ ។

សុវណ្ណៈ	នៅអូរស្វាយហើយទៅនៅណាទៀត?

ហេនៈ	បកមកនៅហ្នឹងវិញ ។

ប្ដីៈ	ដល់ពេលព្រឹត្តិការណ៍កើតឡើងបកមកនៅហ្នឹងវិញ ។

សុវណ្ណៈ	អីចឹងនៅអូរស្វាយបានយូរដែរ?

ហេនៈ	បានយូរ ។

ប្ដីៈ	បានខ្ទង់មួយឆ្នាំដាង ។

ហេនៈ	អេ៎! ៣-៤ឆ្នាំទៅ ព្រោះយើងនៅធ្វើស្រែបាន២-៣ឆ្នាំ ។

សុវណ្ណៈ	អីចឹងចេញពីអូរស្វាយមកនៅណាវិញ?

ហេនៈ	មកនៅទំនប់ដាច់ ។

សុវណ្ណៈ	មកទំនប់ដាច់មុនសមាហរណកម្ម ឬក្រោយសមារណកម្ម?

ហេនៈ	ដាច់ខ្ទួនមួយវគ្គមេៗប្រតិកម្មកើតឡើង ។

សុវណ្ណៈ	ឆ្នាំណា?

ប្ដីៈ	មិនដឹងកោប៉ុន្មាន ។

សុវណ្ណៈ	ព្រោះយើងសមាហរណកម្ម៩៨ ចូលរដ្ឋាភិបាល ។

ប្ដីៈ	ចូលមុន ។

សុវណ្ណៈ	ចូលមុនអាច៩៥-៩៦ យើងចូលមុនបណ្ដើរៗខ្លះ ព្រឹត្តិការណ៍ហ្នឹងអាចពូចាំបានទេ?

ប្ដីៈ	អត់ចាំទេ អត់ចាំថ្ងៃខែ ។

សុវណ្ណៈ	អីចឹងមកកន្លែងនេះមុនសមាហរណកម្មទេ?

ប្ដីៈ	មុន ។

សុវណ្ណៈ	តែមានព្រឹត្តិការណ៍កើតឡើង? អត់ចាំឆ្នាំទេពូ?

ប្ដីៈ	អត់ចាំ អត់បានកត់ត្រាទុកទេ ។

សុវណ្ណៈ	តែនៅបានប្រហែលប៉ុន្មានឆ្នាំដែរ នៅខាងអូរស្វាយ?

ប្ដីៈ	នៅខ្ទង់៣ឆ្នាំដែរ ។

ហេនៈ	ធ្វើស្រែបាន២ដង ។

សុវណ្ណៈ	ក្រោយមកនៅនេះវិញ?

ប្ដីៈ	បាទ!

ហេន៖ ចាំ!

សុវណ្ណ៖ ដល់ពេលមកនៅនេះដំបូងយ៉ាងម៉េចដែរ ស្រុកភូមិនៅនេះមីង?

ហេន៖ ព្រៃ ។

ប្ដី៖ ពីមុនព្រៃច្រើស ។

សុវណ្ណ៖ ដល់យើងឃើញទូលាយអីចឹង ឃើញខុសពីមុនយ៉ាងម៉េចដែរ? ពីមុនយើងធ្លាប់តែសំបូរឈើ ដល់ឥឡូវយើងរាងអស់ឈើ គិតយ៉ាងម៉េចដែរពូឥឡូវ?

ប្ដី៖ មិនដឹងគិតម៉េច ស្រឡះមុខដែរ ។

ហេន៖ វាអស់ធម្មជាតិ ។

សុវណ្ណ៖ សំរាប់មីងផ្ទាល់ មីងពេញចិត្តនឹងការអភិវឌ្ឍន៍បច្ចុប្បន្ននេះទេ? គិតថាយើងពីមុនធម្មជាតិនៅល្អច្រើន ដល់ពេលឥឡូវយើងអស់ឈើ គិតថាយ៉ាងម៉េចដែរមីង?

ហេន៖ គិតថាចង់ដាំជាដំណាំ យុទ្ធសាស្ត្រស្វាយ ខ្នុរ ដូង ។

សុវណ្ណ៖ ខ្ញុំចង់និយាយថាពីមុនយើងធ្លាប់មានឈើច្រើន យើងមានធម្មជាតិរបស់យើងនៅច្រើនពីមុន ដល់ពេលឥឡូវយើងអត់សូវមានឈើ គេកាប់ខ្លះ ចំពោះមីងផ្ទាល់មានកន្លែងណាមីងពេញចិត្តចំពោះការអភិវឌ្ឍន៍ក្នុងពេលបច្ចុប្បន្ននេះ ឬកន្លែងណាដែលមីងមានចំណុចពេញចិត្ត ចំណុចមិនពេញចិត្តមានទេ? ធ្វើកែប្រែស្រុកយើងអត់ដូចពីមុន? ចំណុចពេញចិត្តចំណុចមិនពេញចិត្តមានទេ?

ហេន៖ មិនដឹងពេញចិត្តអី ពេញចិត្តចង់ធ្វើអី ពេញចិត្តចង់ដាំដើមឈើវិញ ។

សុវណ្ណ៖ អភិវឌ្ឍន៍បច្ចុប្បន្នមានកន្លែងណាដែលមីងអត់ពេញចិត្តទេ? ការអភិវឌ្ឍន៍ពេលបច្ចុប្បន្ននេះមានទេ? កន្លែងណាដែលមីងអត់ពេញចិត្ត កន្លែងណាដែលមីងពេញចិត្ត មានអត់? ឥឡូវមីងពេញចិត្តកន្លែងណាខ្លះ?

ហេន៖ ពេញចិត្តអភិវឌ្ឍន៍ចង់ធ្វើអី ចង់ដាំកូនឈើ ឬចង់ដាំជាស្វ៊ី ។

សុវណ្ណ៖ អត់ទេ សំរាប់មីងផ្ទាល់?

ហេន៖ សំរាប់ផ្ទាល់?

សុវណ្ណ៖ មានកន្លែងណាដែលមីងពេញចិត្តនឹងការអភិវឌ្ឍន៍របស់រាជរដ្ឋាភិបាល ពេលបច្ចុប្បន្ននេះអ្វីដែលមីងពេញចិត្តខ្លះ មានអីខ្លះ?

ហេន៖ មិនទាន់យល់ខ្លះ ។

សុវណ្ណៈ មីងសប្បាយចិត្តនឹងការរស់នៅពេលបច្ចុប្បន្ននេះទេ? មីងចូលចិត្តជីវិតរបស់នៅពេលបច្ចុប្បន្នហ្នឹងទេ ព្រោះមីងធ្លាប់ឆ្លងកាត់របបលន់នល់ របបកម្ពុជាប្រជាធិបតេយ្យ ឆ្លងកាត់របបជំនាន់គស្ញ?

ហេនៈ សប្បាយចិត្តខ្លះ សប្បាយចិត្តដែរ វាលែងមានរបបគាបគៀតមិនឲ្យយើងមានសេរីភាពសប្បាយម្យ៉ាងដែលយើងចេះតែ យើងចង់ធ្វើអីក៏បានតាមអំពើចិត្តរបស់យើង ចង់ធ្វើអីក៏បាន ចង់ដាំអីក៏បាន ចង់រកស៊ីអីក៏បាន ។

សុវណ្ណៈ ចុះពីមុនមកមីងមានជីវិតរស់នៅយ៉ាងម៉េចដែរ?

ហេនៈ ពីមុនមក មានដែលការលំបាកខ្លះ លំបាកដោយសារគេគាបមិនឲ្យយើងធ្វើនេះធ្វើនោះបានមិនឲ្យយើងស៊ីឆ្អែតបរិបូរណ៍ ដល់ពេលមកនៅបច្ចុប្បន្ននេះចេះតែចង់មានចិត្តសប្បាយខ្លះ ។

សុវណ្ណៈ មីងការជាមួយពូឆ្នាំណា?

ហេនៈ តាំងពី៨១ ។

សុវណ្ណៈ តាំងនៅខាងខ្មែរ?

ហេនៈ នៅ១០០២ ។

សុវណ្ណៈ មក១០០២មកឆ្នាំណា?

ហេនៈ មក៨១ ។

សុវណ្ណៈ ៨១ការ មកមុន៨១?

ហេនៈ យើងមកអាច៩៩មកនៅនឹង១០០២ ។

សុវណ្ណៈ ៩៩ម៉េចមីង? ៨០?

ប្ដីៈ ៨១ ។

ហេនៈ ៨១ ។

សុវណ្ណៈ អីចឹងមកប៉ុន្មានខែក្រោយមករៀបការទៅ?

ហេនៈ ចាំ!

សុវណ្ណៈ មីងនៅតាមសាលារៀនឥឡូវគេឲ្យកូនសិស្សរៀនប្រវត្តិសាស្ត្ររឿងខ្មែរក្រហម ពី៧៥-៧៩ មីងយល់ឃើញថាការរៀនសូត្ររបស់កូនសិស្សហ្នឹង គួរតែរៀន ឬមិនគួររៀនទេ? សំរាប់ក្មេងៗតាមសាលារៀន? ព្រោះឥឡូវក្មេងៗតាមវិទ្យាល័យគេមានឲ្យកូនសិស្សរៀនប្រវត្តិសាស្ត្រនៅថ្នាក់រៀន មីងគិតថាប្រវត្តិសាស្ត្រហ្នឹងគួរតែរៀន ឬមិនគួររៀនទេ?

ហេនៈ គួរតែរៀនដែរ គួរតែចាំខ្លះ ។

សុវណ្ណៈ មូលហេតុអីមីងគួរតែរៀនមីង?

ហេនៈ ដូចថាឲ្យវាឃើញដូចថាប្រវត្តិសាស្ត្រពីមុនមកគេធ្វើយ៉ាងណាៗ ចង់ឲ្យវារៀនយល់ដឹងកាល ពីរបបសម័យនោះវាធ្វើយ៉ាងម៉េច របបសម័យនេះគេធ្វើយ៉ាងម៉េច ។

សុវណ្ណៈ ការរៀនហ្នឹងវាសំខាន់ទេមីង?

ហេនៈ សំខាន់ ។

សុវណ្ណៈ សំខាន់បែបម៉េចមីង?

ហេនៈ សំខាន់ដូចថាចង់ឲ្យវាយល់ពីច្បាប់សម័យមុនវាដូចម្ដេច ច្បាប់សម័យក្រោយនេះវាយ៉ាង ម៉េច វាធូរស្បើយជាងមុនខ្ញុំនឹកឃើញអីចឹង ។

សុវណ្ណៈ មីងនៅពេលបច្ចុប្បន្ននេះសំរាប់ជីវិតមីងរស់នៅដែលធ្លាប់ឆ្លងកាត់ពីមុនមក ហើយមកដល់ ពេលបច្ចុប្បន្ននេះមីងមានផលលំបាកអីក្នុងខ្លួនទេ? ដែលសល់ពីសម័យមុនមក សល់ពីជំ នាន់តស៊ូ សល់ពីជំនាន់សង្គ្រាមអីមក សំរាប់ខ្លួនមីងផ្ទាល់អី?

ហេនៈ អត់មានផលលំបាកអីទេនេះ ។

សុវណ្ណៈ ដូចគេងយប់ឡើងតែងតែនឹកឃើញរឿងរត់កាត់គ្រាប់ពីមុនមក?

ហេនៈ ពេលដូចថាយើងនឹកឃើញម្ដងៗ នឹកឃើញថាពីសម័យមុនយើងរត់ លំបាកលំបិន ត្រដាប ត្រដួសខំរត់គេចពីគ្រាប់ ពីរំសេវ ពីយួន ។

សុវណ្ណៈ ពេលដែលមីងនឹកឃើញអីចឹងអារម្មណ៍មីងបែបម៉េចទៅ?

ហេនៈ អារម្មណ៍ភ័យខ្លាច ។

សុវណ្ណៈ មីងធ្វើម៉េចបានបាត់ភ័យខ្លាចវិញ?

ហេនៈ ចេះតែបន្ធូរបន្ថយអារម្មណ៍ទៅ កុំគិត ជីវិតចំណាស់នេះហើយ នឹកឃើញថាបើម៉េចក៏ម៉េច ទៅទៀតទៅចុះ បើរត់ក៏រត់ គេវ៉ៃក៏វ៉ៃទៅទៀតចុះ ។

សុវណ្ណៈ មីងមានដែលនិយាយរឿងប្រវត្តិឆ្លងកាត់របស់មីង ដូចខ្ញុំសួរមីង មីងប្រាប់ខ្ញុំអីចឹង មីងមានដែលនិយាយជាមួយកូន និយាយជាមួយចៅប្រាប់កូនចៅខ្លះទេ?

ហេនៈ និយាយប្រាប់ ។

សុវណ្ណៈ ច្រើននិយាយរឿងអីប្រាប់ដល់កូនៗ ដល់ចៅៗ?

ហេនៈ និយាយរឿងប្រាប់រត់លំបាក លំបិនពីមុនមកយើងរត់កាត់គ្រាប់ រត់ឱបកូនចៅ រត់កាត់ ឡើងភ្នំ ចុះភ្នំ បន្ទាប់មុតចេះតែនិយាយប្រាប់ទៅ ។

សុវណ្ណៈ ដល់ពេលនិយាយប្រាប់អីចឹងកូនថាម៉េច?

ហេនៈ ចេះតែអង្គុយស្ដាប់ទៅ ។

សុវណ្ណៈ អត់មានសួរនាំមកវិញខ្លះទេ?

ហេនៈ វាសួរ ៗ ម៉ែបើរត់អីចឹង គ្រាប់ ឆ្លងឡើងភ្នំ មុតបន្លា ម៉ែឯងអត់ភ័យខ្លាច បងយំ ចេះតែសួរ ៗ

សុវណ្ណៈ មីងឆ្លើយប្រាប់វិញថាម៉េច?

ហេនៈ ឆ្លើយថា «អើ! ធ្វើម៉េច ចេះតែយកដៃខ្ទប់មាត់ ខ្ទប់មុខវាទៅកុំឲ្យវាយំ» ៗ

សុវណ្ណៈ សព្វថ្ងៃកូនមីងនៅរៀនខ្លះទេ ឬអត់ទេ?

ហេនៈ អត់មានទេ មានតែចៅ២នាក់កំពុងរៀន ៗ

សុវណ្ណៈ រៀនហ្នឹងចង់ឲ្យចៅធ្វើអីគេទៅថ្ងៃអនាគត?

ហេនៈ សួរចំណង់របស់វា វាចង់ខាងអី ៗ

សុវណ្ណៈ តែសំរាប់ខ្លួនមីងផ្ទាល់ មានដែលនឹកឃើញរៀបគំរោងអីឲ្យចៅៗ ថាត្រូវរៀននេះសំរាប់ធ្វើអី មានដែលគិតខ្លះទេ?

ហេនៈ គិតខ្លះដែរ តែមើលសមត្ថភាពរបស់ចៅដែរ បើចៅណារៀនបានលូតលាស់បានរីកចំរើន ចេះតែនឹកឃើញឲ្យចៅធ្វើដូចថាធ្វើជាពេទ្យក៏បាន ធ្វើគ្រូបង្រៀនអីចឹង ៗ

សុវណ្ណៈ មីងគិតថាការអប់រំសំខាន់ទេសំរាប់ចៅៗរបស់មីង សំរាប់កូនៗរបស់មីង គិតថាការអប់រំសំខាន់ទេការអប់រំ ការរៀនសូត្រ?

ហេនៈ សំខាន់ ៗ

សុវណ្ណៈ សំខាន់យ៉ាងម៉េចមីង?

ហេនៈ ដឹកនាំឲ្យចៅល្អ ឲ្យចេះដឹង ចេះគោរព ៗ

សុវណ្ណៈ មីងមានអីចង់បន្ថែមខ្លះ ឬក៏មានអីចង់សួរខ្ញុំខ្លះ កន្លែងណាខ្ញុំអត់សួរមីង មីងសួរនាំខ្ញុំវិញ ឬក៏មីងមានគំនិតអីចង់បន្ថែមអ្វីដែលខ្ញុំមិនសួរមីង មានអីខ្លះទេ? មានអីជាបន្ថែមជាយោបល់ខ្លះទេ?

ហេនៈ គ្មានយោបល់អីទេនេះ ៗ

សុវណ្ណៈ អីចឹងខ្ញុំដូចជាជួបមីងច្រើន រំខានមីងច្រើនមកហើយ ៗ

ហេនៈ អត់អីទេរីករាយផ្តល់ឲ្យ ៗ

សុវណ្ណៈ អីចឹងខ្ញុំប៉ុណ្ណឹងអរគុណច្រើនមីង ៗ

ហេនៈ ចា៎!

**ចប់**